# និរយកថា

សំដែងអំពីស្ថាននរក


អ្នកមហា ឌុម-ណាគ្រី

រៀបរៀង


ឧទ្ទិស

បំពោះប្រជានិករទូទៅក្នុងកម្ពុជរដ្ឋ


ការផ្សាយរបស់

បណ្ណាគារ ជឹង-ប៉ោ-ប្លូត លេខ ១១៤០

វិថីព្រះបាទគេគ្គសេន ក្រុងភ្នំពេញ

ផ្សាយចេញពី

# www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# និរយកថា

សំដែងអំពីស្ថាននរក


អ្នកមហា ឌុម-ណាគ្រី

រៀបរៀង


ឧទ្ទិស

បំពោះប្រជានិករទូទៅក្នុងកម្ពុជរដ្ឋ


ការផ្សាយរបស់

បណ្ណាគារ ជឹង-ប៉ោ-ហ្មត លេខ ១៤០

វិថីព្រះបាទអង្គអេង ក្រុងភ្នំពេញ

# អារម្ភកថា

"និរយកថា" នេះ ជាច្បាប់សំដែងប្រាប់អំពីរឿងនរក; សេចក្តីទុក្ខទោសរបស់សត្វអ្នកនៅក្នុងនរក ជាផលបាបដែលខ្លួនបានប្រព្រឹត្តតើក្នុងកាលកើតជាមនុស្ស លុះទម្លុះកាយទម្លាយខ្លួន ក៏នឹងបានទៅកាន់កំណើតកើតក្នុងនរក រមែងបានសេចក្តីទុក្ខលំបាកកាយលំបាកចិត្ត រងទុក្ខវេទនាដ៏ក្រៃលែង ។

ឋាននរក បើតាមដំណឹងដែលមានមកក្នុងផ្លូវព្រះពុទ្ធសាសនា ជាឋានមានសេចក្តីទុក្ខលំបាកវិសេសប្លែកអំពីឋាននានា ដែលមាននៅក្នុងមនុស្សលោក, ពួកមនុស្សជាបុថុជ្ជនទាំងឡាយ ពុំអាចទៅឃើញផ្ទាល់ភ្នែកបានឡើយ មានតែពួកព្រះអរិយបុគ្គល ដែលចេះដឹងនូវចិត្តសាស្ត្រ ជាអ្នកមានឥទ្ធិឫទ្ធិទើបទៅឃើញផ្ទាល់ភ្នែកបាន ។ ក្នុងពុទ្ធកាល មានដំណាលថា សម័យថ្ងៃមួយព្រះមហាមោគ្គល្លានត្ថេរ ដែលជាអ្នកមានឫទ្ធិច្រើន បានសូមពុទ្ធានុញ្ញាតហើយចូលឈានទៅមើលឋាននរក បានពិនិត្យមើលនូវស្ថានភាពទុកដី របស់ស្ថានទាំងនោះដោយសព្វគ្រប់ ក៏ត្រឡប់មកឋានមនុស្សវិញ បានប្រកាសផ្សាយពត៌មាននេះ ប្រាប់ដល់ពួកមនុស្សទាំងឡាយ ដែលនៅក្នុងសកលនិគមជនបទទាំងពួង ៗ ក្នុងពេលនោះ ពួកមនុស្សទាំងឡាយ ក៏បានដឹង[illegible]ស្គាល់ថាមានឋាន

នរកដោយជាក់ច្បាស់ ។

ព្រោះហេតុដែលខ្ញុំបានឃើញរឿងការយ៉ាងនេះហើយ បានជាខ្ញុំទាញយកគម្ពីរដីកាក្បួនច្បាប់ដែលមាននិយាយពីឋាននរក មករៀបរៀងជាសៀវភៅ ដើម្បីជាប្រយោជន៍ដល់សិក្ខាកាមនិករទាំងឡាយទូទៅ ។

ខ្ញុំរៀបរៀងជាពីរច្បាប់ គឺ ១ និយាយពីឋាននរក ខ្ញុំឲ្យឈ្មោះថា " និរយកថា " ; ២ និយាយពីឋានសួគ៌ ខ្ញុំឲ្យឈ្មោះថា " សគ្គកថា " លុះរៀបរៀងចប់ហើយ ខ្ញុំបានប្រគល់សៀវភៅទាំងពីរច្បាប់នេះឲ្យសិទ្ធិផ្ដាច់ទៅ លោក ជីន.ប៉ៅ ដើម្បីចាត់ការបោះពុម្ពផ្សាយទូទៅក្នុងសកលកម្ពុជរដ្ឋ ។

ដោយវីរិយភាពរបស់ខ្ញុំនេះ

សូមសន្តិសុខចូរមានដល់សកលលោក ។

សូមជ័យជោគយោគយិតយោងកម្ពុជា ។

សូមរលាយពាយរលត់បាត់ទៅ ។

សូមបភាពពុទ្ធសាសន៍រុងរឿងអើយ ។

ព្រះមហា ឌុម-ណាគ្រី

ខេត្តបាត់ដំបង នៅភូមិដាំ ឃុំស្វាយប៉ៅ ស្រុកសង្កែ

# និរយកថា

*សំដែងអំពីរឿងក្នុងនរក*

នមោ តស្ស ភគវតោ អរហតោ សម្មា-សម្ពុទ្ធស្ស ៗ

សូម សំដែងពន្យល់អំពីឋាន នរក និងសេចក្ដីទុក្ខរបស់សត្វដែលវិបត្តិកំណើតទៅកើតក្នុងនរក ដោយអំណាចអកុសលផល បាបដែលខ្លួនបានកសាងត្រដាងទុកជាតួយ៉ាង ដូចតទៅនេះ

ពាក្យថា **នរក** មកពីពាក្យថា **និរយៈ** ប្រែថា មិនមានសេចក្ដីចំរើន, អធិប្បាយថា មិនមានសេចក្ដីចំរើនដោយទ្រព្យ យសសុខ សរសើរ មានតែដំណើរទុក្ខបុកម្នេញទោមនស្សវេទនាជាចំណែកមួយ ទីនរកសេចក្ដីសុខសូម្បីបន្ដិចបន្តួចក៏គ្មាន គឺថាមិនមានសេចក្ដីសុខក្នុងការ ដើរ ឈរ អង្គុយ ដេក ស៊ី ផឹក ស្លៀក និយាយ គិត និងសុខក្នុងកាមសេវនកិច្ចក៏មិនមានឡើយ សូមប្រៀបធៀបល្មមឲ្យចូលចិត្តបានដូចតទៅនេះគឺ សុខរបស់មនុស្សច្រើនជាងសុខរបស់សត្វតិរច្ឆាន សុខរបស់សត្វតិរច្ឆានច្រើនជាងសុខរបស់អសុរកាយ សុខរបស់អសុរកាយច្រើនជាងសុខរបស់ប្រេត សុខរបស់ប្រេតគ្រាន់បើជាងសុខរបស់នរក ៗ កាលបើធៀបចុះមកតាមលំដាប់ដូច្នេះ អាចឃើញបានថាក្នុងនរកមិនមានសេចក្ដីសុខឡើយ ៗ កាលបើមិនទាន់ចូលចិត្ត សូមបំបែកញែកមនុស្ស

ទៅជា ៤ ប្រភេទ   គឺសុខរបស់មនុស្សទេព   គឺមនុស្សដែលបរិបូណ៌ពោរពេញដោយទ្រព្យ សុខ យស សរសើរ នឹងបរិបូណ៌ដោយគុណធម៌មាន ហិរិ ឱត្តប្បៈជាដើម ជាសុខដែលច្រើនជាងសុខរបស់មនុស្សតិរច្ឆាន គឺមនុស្សដែលដុនដាបទាបថោករកចិញ្ចឹមជីវិតក្នុងផ្លូវទុច្ចរិត,   សុខរបស់មនុស្សតិរច្ឆានគ្រាន់បើជាងសុខរបស់មនុស្សអសុរកាយ   គឺមនុស្សដែលមានរាងកាយវិកលវិការវិបត្តិដោយខ្វាក់ខ្វិន   ខ្វក់ខ្វិត   គរាំងគំរាំង គរិល គំរក់គក្រួតមានមុខមាត់គួរខ្ពើមមិនជាទីពិតពិលរមិលមើលរបស់ជនានុជន, សុខរបស់មនុស្សអសុរកាយ គ្រាន់បើជាងសុខរបស់មនុស្សប្រេតគឺមនុស្សដែលក្រលំបាកយ៉ាកយ៉ាប់អព្វមង្គល ទុព្វលភាព មិនមានផ្ទះសម្បែងកន្លែងស្ថានសម្រាប់នៅជ្រកកោន   ខ្វះខាតគ្រឿងឧបភោគបរិភោគ   សម្លៀកសំពត់សម្រាប់ស្លៀកដណ្តប់បិទបាំងរាងកាយ   និងថ្នាយសម្ងសម្រាប់បរិភោគចិញ្ចឹមជីវិត   ឲ្យបិតរស់នៅក្នុងមួយថ្ងៃ ៗ ក៏រកបានក្រ   ត្រដាបត្រដួសត្រដ្រួលត្រដែសហួសខ្នាត   បានដល់យាចក   អ្នកសូមដើរសូមទានគេដោយច្រកល្ហកដៀង ៗ សុខរបស់មនុស្សប្រេតបែបនេះ   ក៏នៅគ្រាន់បើជាងសុខរបស់សត្វតិរច្ឆាន   សត្វតិរច្ឆានក៏នៅមានបំបែកញែកទៅទៀតជាច្រើនប្រភេទ ប្រភេទខ្ពស់ខ្លះ កណ្តាលខ្លះ ទាបខ្លះ ទាបទីបំផុតខ្លះ តែនៅ

មានសុខច្រើនជាងអសុរកាយ អសុរកាយនៅមានសុខច្រើនជាងប្រេត ។ ក៏បំបែកចែកចេញជាច្រើនប្រភេទតែប្រេតគ្រប់ប្រភេទ សូម្បីប្រភេទដែលរាប់ថាទុក្ខទីបំផុត គឺមិនមានគ្រឿងសំលៀកបំពាក់មិនមានទីនៅទីដេកអត់បាយក្រហាយទឹករាប់អស់ទាំងកប្ប ។ ដូចយ៉ាងពួកប្រេតដែលជាញាតិរបស់ព្រះបាទពិម្ពិសារ ដែលតោកយ៉ាកលំបាកអត់ឃ្លានតាំងនៅ ៩១កប្បជាតួយ៉ាង សូម្បីប្រេតទាំងនោះក៏នៅរាប់ថា មានសុខច្រើនជាងសត្វនរកៗ នោះបំបែកចែកចេញជា ៣ប្រភេទ តាមប្រភេទដែលធ្លាក់ក្នុងនរក រណ្តៅតូច រណ្តៅកណ្តាល រណ្តៅធំ ។

ដោយហេតុនេះលោកទើបពោលថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់គ្រប់ៗអង្គ តែងទ្រង់ប្រកាសត្រាស់សំដែងថ្លែងរឿងនរក ប្រេតអសុរកាយ សត្វតិរច្ឆាន ស្ថានសួគ៌ និព្វាន ទុកដើម្បីឲ្យជនទាំងឡាយដែលស្អប់សេចក្តីទុក្ខស្រឡាញ់សេចក្តីសុខ ហើយលះបង់សេចក្តីអាក្រក់ធ្វើសេចក្តីល្អ ដើម្បីឲ្យបានទទួលនូវផលសុខខ្ពស់ឡើង សមគួរតាមបំណងប៉ងប្រាថ្នា តែទ្រង់សំដែងទុកដោយន័យផ្សេងៗ សង្ខេបខ្លះ ពិស្តារខ្លះ តាមសមគួរដល់វេលានិងឧបនិស្ស័យនៃអ្នកស្តាប់ ៗ ដែលទ្រង់សំដែងរឿងនរកនោះ មានប្រាកដនៅក្នុងទេវទូតសូត្រជាដើម ដូចអធិប្បាយតទៅនេះ ៖

នរកដែលព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ប្រកាសទុកក្នុងទេវទូតសូត្រ នោះមាន ៧ គឺ

១ លោហកុម្ភីនរក - នរកនេះជាខ្ទះទង់ដែងពេញទៅដោយទឹកទង់ដែងពុះក្រគ្រក់ខ្ពុល ៗ មានគាថាជាគ្រឿងសំអាងថា

សជោតិភូតា ជលិតា បទិត្តា
បទិស្សតិ មហតី លោហកុម្ភី ៗ

ប្រែថា « លោហកុម្ភីនរក មានទឹកទង់ដែងដ៏ក្តៅ ឆេះជាអណ្តាតភ្លើងទៅជានិច្ច » ៗ ក្នុងអដ្ឋកថាពន្យល់ថា លោហកុម្ភីនរកនេះជាខ្ទះទង់ដែងដ៏ធំ ទំហំប្រមាណប៉ុនភ្នំ ពេញប្រៀបទៅដោយទឹកទង់ដែងតាំងនៅរហូតអស់កប្ប; ខ្ទះទង់ដែងនោះ បើវាស់ពីមាត់ទៅដល់បាតជម្រៅ៦០ យោជន៍ ៗ

ពួកនាយនិរយបាល ចាប់សត្វនរកបោះចុះទៅក្នុងខ្ទះទង់ដែងនោះ សត្វនរកទាំងឡាយក៏អណ្តែតចុះអណ្តែតឡើងនៅក្នុងខ្ទះ មានអាការៈហាក់ដូចជាគ្រាប់អង្ករដែលកំពុងពុះខ្ពុល ៗ នៅក្នុងឆ្នាំងដ៏ក្តៅដូច្នោះនឹងលិចចុះទៅយូរយារណាស់ចំនួន ៣០.០០០ឆ្នាំ ទើបដល់បាតខ្ទះ កាលដល់ហើយក៏អណ្តែតឡើងវិញចំនួន ៣០.០០០ឆ្នាំដែរ ទើបដល់មាត់ខ្ទះ គ្រាន់តែលិចចុះនឹងអណ្តែតឡើងរួមទៅត្រូវជា ៦០.០០០ឆ្នាំ បើនៅមិន

ទាំងអស់ បាបកម្មដ៏ទាបណា ក៏នៅតែលិចចុះនឹងអណ្ដែតឡើងដាបនោះ ។

ក្នុងអដ្ឋកថាធម្មបទ ភាគ ៣ ទំព័រ ១៧៩ មានដំណាលអំពីសេដ្ឋីបុត្រ ៤នាក់ ដែលធ្លាក់ក្នុងលោហកុម្ភីនរក ដូចសាធកៈតទៅនេះ ។

អតីតេ កាលេ កាលដ៏កន្លងទៅហើយ ព្រះដ៏មានព្រះភាគព្រះនាមកស្សបៈ ទ្រង់ឧប្បត្តិឡើងក្នុងលោក ក្នុងកាលដែលមនុស្សទាំងឡាយមានអាយុ ២០.០០០ ឆ្នាំ ព្រះអង្គនិមន្តទៅកាន់ចារិកមួយអន្លើដោយព្រះខីណាស្រព ២០.០០០ អង្គ ។ ពួកអ្នកនគរពារាណសី ក៏ប្រាតខ្ទី ប្រមូលគ្នាធ្វើអាគន្តុកទាន ។

គ្រានោះ មានសេដ្ឋីបុត្រ ៤ នាក់ជាសំឡាញ់នឹងគ្នា មានសម្បត្តិ ៤០ កោដិនៅក្នុងនគរពារាណសី បានប្រឹក្សាគ្នាថា ទ្រព្យសម្បត្តិយើងមានច្រើន តើយើងនឹងប្រកបការងារដូចម្ដេច? កាលដែលព្រះសម្មាសម្ពុទ្ធស្ដេចកំពុងយាងទៅកាន់ចារិកយ៉ាងនេះ ក៏សេដ្ឋីបុត្រទាំង ៤ នាក់នោះឥតមាននិយាយយ៉ាងនេះថា (យើងទាំងឡាយនឹងឲ្យទាននឹងបូជានឹងរក្សាសីល) ដូច្នេះសោះ បែរជានិយាយយ៉ាងនេះថា បើយើងទាំងឡាយ ផឹកស្រាឲ្យស្រវឹង ហើយស៊ីសាច់ដែលមានរសឆ្ងាញ់ពិសា ទើបពេញជាការរស់នៅមានប្រយោជន៍ ។ ម្នាក់ទៀតនិយាយថា យើងត្រូវតែបរិភោគបាយអង្ករស្រូវ...

ដែលមានកូនក្រមុំនិងវត្ថុមានរសផ្សេង ៗ ។ ម្នាក់ទៀតនិយាយថា យើង ចាយប្រាក់ឲ្យពួកស្រី ៗ ទោះបីកូនប្តីប្រពន្ធគេក៏គង់តែស្ម័គ្រចិត្តនឹងយើង មិនខាន ហើយយើងនឹងធ្វើនូវបរទារកម្មឲ្យពេញបន្ទុក ។

សេដ្ឋីបុត្រទាំង ៤ នោះយល់ព្រមព្រៀងគ្នាហើយ ចាប់ដើមពីថ្ងៃ នោះមកក៏តែងបញ្ជូនទ្រព្យទៅឲ្យស្រីទាំងឡាយដែលមានរូបល្អ ៗ ហើយ ធ្វើនូវបរទារកម្មអស់ ២០.០០០ ឆ្នាំ លុះធ្វើមរណកាលទៅ ក៏ទៅកើតក្នុង អវិចិមហានរកអស់មួយបន្ទោះព្រះពុទ្ធ ស្លាប់រួចពីអវិចិនរក ទៅកើត ក្នុងនរកលោហកុម្ភីជម្រៅ ៦០ យោជន៍ លិចចុះទៅអស់ ៣០.០០០ ឆ្នាំ ទើបដល់បាតខ្ទះអណ្តែតឡើងអស់ ៣០ ០០០ ឆ្នាំទើបដល់មាត់ខ្ទះ ហើយ ចង់ពោលគាថាមួយម្នាក់ ៗ ប៉ុន្តែមិនអាចពោលបាន ក៏ពោលត្រឹមតែ អក្ខរៈមួយតួម្នាក់ហើយក៏ត្រឡប់លិចចុះក្នុងខ្ទះទង់ដែងវិញ ។

៙ គាថាដែលសត្វនរកទី ១ ប្រុងនឹងពោលនោះយ៉ាងនេះថា

ទុ – ទុជ្ជីវិតមជីវិម្ហា យេសន្តេ ន ទទាម្ហសេ
វិជ្ជមានេសុ ភោគេសុ ទីបំ នាកម្ហ អត្តនោ ។

យើងទាំងឡាយមានជីវិតដ៏លាមក បានរស់នៅហើយ ; កាលដែល ភោគសម្បត្តិកំពុងមាន យើងទាំងឡាយមិនបានឲ្យទានសោះ យើង

ទាំងឡាយ មិនបានធ្វើនូវទីពឹងរបស់ខ្លួនសោះ ។

គាថាដែលសត្វនរកទី ២ បម្រុងនឹងពោលនោះយ៉ាងនេះថា

ស - សដ្ឋីវស្សសហស្សានិ បរិបុណ្ណានិ សព្វសោ

និរយេ បច្ចមានានំ កទា អន្តោ ភវិស្សតិ ។

យើងទាំងឡាយដែលបាបកម្មចំអិនទៅក្នុងនរកនេះអស់ ៦ ហ្មឺនឆ្នាំ ពេញគ្រប់គ្រាន់មិនមានលើសខ្វះ ទេ? កាលណាហ្ន៎ នឹងមានទីបំផុតនៃសេចក្តីទុក្ខ ។

គាថាដែលសត្វនរកទី ៣ បម្រុងនឹងពោលនោះយ៉ាងនេះថា

ន - នត្ថិ អន្តោ កុតោ អន្តោ បដិទិស្សតិ

តទា ហិ បកតំ បាបំ មម តុយ្ហញ្ច មារិស ។

ទីបំផុតនៃសេចក្តីទុក្ខរបស់យើងទាំងឡាយ មិនមានឡើយ , មានទីបំផុតនៃសេចក្តីទុក្ខពីណា ; ទីបំផុតនៃសេចក្តីទុក្ខមិនប្រាកដទេ ; ម្នាលអ្នកដូចជាខ្ញុំ , ដ្បិតពីក្នុងកាលនោះ ខ្ញុំនិងអ្នកទាំងឡាយបានធ្វើបាបពេញបន្ទុកណាស់ ។

គាថាដែលសត្វនរកទី ៤ បម្រុងនឹងពោលនោះយ៉ាងនេះថា

សោ -សោហំ នូន តតោ គន្ត្វា យោនឹ លទ្ធាន មានុសឹ

វទញ្ញូ សីលសម្បន្នោ កាហាមិ កុសលំ ពហុំ ។

បើខ្ញុំបានរួចអំពីទីនេះទៅ ហើយបានកំណើតជាមនុស្ស នឹងជាអ្នកដឹងនូវពាក្យពេចន៍បរិបូណ៌ដោយសីល នឹងធ្វើតែកុសលយ៉ាងច្រើន ។

រឿងនេះ លើកមកបញ្ជាក់អំពីលោហកុម្ភីនរក ដែលបានដំណាលពីខាងដើម ។

បាបកម្មដែលធ្លាក់នរកនេះ លោកពោលទុកតែដោយខ្លីថាបានដល់ការជេរបញ្ចោរសមណព្រាហ្មណ៍អ្នកមានសីលប៉ុណ្ណោះ មានគាថាក្នុងនេមិរាជជាតកជាគ្រឿងសំអាងថា

យេ សីលវំ សមណំ ព្រាហ្មណំ វា

ហឹសេន្តិ រោសេន្តិ សុបាបធម្មា

តេ លុទ្ទកម្មា បសវេត្វ បាបំ

តេមេ ជនា លោហកុម្ភឹ បតន្តិ ។

ប្រែថា មនុស្សមានចិត្តអាក្រក់ណា បៀតបៀនជេរបញ្ចោរសមណព្រាហ្មណ៍អ្នកមានសីល មនុស្សដែលមានចិត្តអាក្រក់ទាំងនោះ លុះ

ធ្វើសេចក្តីអាក្រក់ហើយ រមែងធ្លាក់លោហកុម្ភីនរក ។

គន្ថអដ្ឋកថាពន្យល់ថា មនុស្សប្រមានចិត្តទុច្ចរិតលាមកបោកទាបទាំង នោះ រមែងត្រូវនាយនិរយបាលចាប់កជើងឡើងលើយកក្បាលសំយុង ចុះក្រោម ហើយបោះចុះទៅក្នុងខ្ទះទង់ដែង ។

និពន្ធគាថាខាងលើនេះ បញ្ជាក់ឲ្យឃើញថា ការជេរបញ្ចោរសម-ណព្រាហ្មណ៍ អ្នកមានសីលនាំឲ្យធ្លាក់លោហកុម្ភីនរក តែបើតាមអដ្ឋកថា ធម្មបទ ការប្រព្រឹត្តក្នុងកាមប្បវេណី នឹងកូនប្រពន្ធអ្នកដទៃក៏ជាហេតុឲ្យ ធ្លាក់នរកនេះដែរ ដូចនិទានសេដ្ឋីបុត្រ ៤ នាក់ដែលសាធកៈរួចមកហើយ ។

**២ អវិចិនរក** - ជានរកធំ មានជ្រុង ៤ មានទ្វារ ៤ ឡោមព័ទ្ធ ព័ទ្ធជុំវិញដោយកំពែងដែក ។ សជាដែកនេះជាអណ្តាតភ្លើងដ៏សន្ធោ សន្ធៅរន្ទាលព្រាលឆ្អៅនៅជានិច្ច អណ្តាតភ្លើងនោះស្ទុះចំហាយផ្សាយកំ-ដៅទៅបានចម្ងាយ ១០០ យោជន៍ មានអណ្តាតភ្លើងឆេះឡើងអំពីជញ្ជាំង ទិសខាងកើត រាលដាលហួតដល់ជញ្ជាំងទិសខាងលិច ឆេះអំពីជញ្ជាំង ទិសខាងលិច រាលដាលទៅដល់ជញ្ជាំងទិសខាងកើត ឆេះអំពីជញ្ជាំង ទិសខាងជើង អណ្តាតភ្លើងរាលដាលទៅដល់ជញ្ជាំងទិសខាងត្បូង ឆេះ អំពីជញ្ជាំងទិសខាងត្បូង រាលដាលដល់ជញ្ជាំងទិសខាងជើង ឆេះអំពី

ក្រោមទៅលើ ឆេះពីលើមកក្រោម ៗ

- ក្នុងអដ្ឋកថាមានសេចក្ដីពន្យល់ថា អវិចិនរកនោះ បើរាស់ទទឹងនិងបណ្ដោយ ដោយជុំវិញមាន ៩០០ យោជន៍ ផ្ទាំងកម្រាលខាងក្រោមជាទង់ដែង គម្របខាងលើក៏ជាទង់ដែងដែរ កំពែងនៃនរកនេះមួយខណ្ឌៗ កម្រាស់ ៩ យោជន៍ មានអណ្ដាតភ្លើងឆេះឡើងអំពីកំពែងទាំង ៤ ខណ្ឌ ប្រជួបប្រសព្វគ្នាទាំងអស់រាប់ទាំងបរិវេណ។ ស្រុកនរកផងជាម៉ឺនយោជន៍ៗ

ពពួកសត្វដែលធ្លាក់ចុះក្នុងអវិចិនរកនេះ មានភ្លើងឆេះស្រោបអោយជុំវិញខ្លួនរកទីពួនទីពឹងគ្មាន កាលត្រូវភ្លើងឆេះក៏គិតត្រិះរិះរកច្រកល្ហកចេញចាកនរកជានិច្ច តែគ្មានច្រកនឹងចេញសោះ ក្នុងស្រណោះស្រណោកខំរត់ដេញគ្នាទៅវិញទៅមករកកន្លែងចេញ គិតឃើញថានឹងចេញតាមទ្វារខណ្ឌដូចខាងកើតបាន ក៏បែរមុខនោះទៅកាន់ទិសបូព៌ាម្នារតតម្រង់ត្រង់សំដៅទៅឋានប្រញាប់ប្រញាល់ ទំរាំតែនឹងបានដល់ក៏យូរយារណាស់ៗ ក្នុងខណៈដែលកំពុងរត់ទៅក៏ត្រូវភ្លើងឆេះ សម្បុរថ្ងៃ ឆេះឆ្អុះទាំងស្បែក សាច់ឆ្អឹងនិងសរសៃ លុះទៅដល់ហើយឃើញទ្វារបិទក៏ចេញមិនបាន ត្រូវទទួលទុក្ខវេទនាឥតស្រាកស្រាន្តដ៏យូរយារ រហូតដល់អស់បាបកម្ម កាលបាបកម្មនៅមិនទាន់អស់ ក៏ត្រឡប់រស់មានរាងកាយបរិបូណ៌ឡើងវិញ

ហើយគេត្រឡប់មកទារ ចំណាខាងលិចខ្លះ ខាងជើងខ្លះ ខាងត្បូងខ្លះ ប្រទះត្រូវភ្លើងឆេះឆួលពោលពាសន្ធោសទៅគ្រប់ដំហាន កាលរួចចាកអវីចិនរកនេះហើយ ក៏ត្រូវធ្លាក់ឧស្សទនរកទៀតរហូតអស់បាបកម្ម ។

ព្រះអដ្ឋកថាចារ្យលើកយករឿងភិក្ខុឈ្មោះទេវទត្តមកពន្យល់ថា កាលទេវទត្តទទួលមរណភាពហើយ បានទៅកើតក្នុងអវីចិនរក មានមាឌកាយកំពស់១យោជន៍ ជើងទាំងពីរជាន់លិចចុះទៅក្នុងផែនដែកដ៏ក្រហមឆ្អៅត្រឹមកជើង ដៃទាំងពីរលិចចុះទៅក្នុងផែនដែកត្រឹមកដៃ ក្បាលលិចចុះក្នុងគម្របខាងលើត្រឹមគុម្ពត្រចៀកទាំងពីរ មានចម្រូងដែកធំប៉ុនដើមត្នោត ចាក់ដោតទម្លុះកាយទម្លាយអំពីទ្រូងមកដល់ខាងខ្នង ធ្លុះអំពីស្តាំធ្លាយទៅខាងឆ្វេង មានចម្រូងដែកធ្លុះមកអំពីទិសទាំង៤ជៀបក្បាលទេវទត្តជាប់នៅនឹងថ្កល់តែមួយកន្លែង កម្រើកកក្រើកងាករេមិនបានឡើយ ហើយមានអណ្តាតភ្លើងឆេះឆួលមកពីទិសទាំង ៤ ជួបជួនប្រសព្វគ្នា ខាងក្រោមឆេះរាលទៅខាងលើ ខាងលើឆេះរាលទៅខាងក្រោម ធ្វើខ្លួនទេវទត្តឲ្យក្រហមឆ្អៅដូចដែកក្រហមទាំងថ្ងៃទាំងយប់ ឥតឈប់ឥតឈរក្រហាយក្រហល់ទល់ទុក្ខវេទនាវង់ទោសអស់កាលដ៏យូរ ព្រោះទោសបៀតបៀនព្រះពុទ្ធជាម្ចាស់ ។

" អវីចិនរក " នេះប្រែថា " មិនទំនេរ, មិនចន្លោះ " អធិប្បាយថា

មិនចន្លោះបាកអណ្ដាតភ្លើង ១ មិនចន្លោះបាកសត្វនរក ១ មិនចន្លោះបាកទុក្ខ ១ គឺអណ្ដាតភ្លើងនោះសត្វនរក នឹងសេចក្ដីទុក្ខមាននៅជានិច្ច ។

អវីចិនរក ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ប្រកាស ត្រាស់សំដែងទុកក្នុងទេវទូតសូត្រមិនមានកំណត់អាយុ នរកដទៃទៀតក៏មិនមានដូចគ្នា ក្នុងអដ្ឋកថារបស់ទេវទូតសូត្រក៏មិនមាន, បំណែកខាងសំយុត្តនិកាយសគាថវគ្គ នឹងទសកនិបាត អង្គុត្តរនិកាយព្រមទាំងបាលីនឹងអដ្ឋកថា មានកំណត់អាយុក្នុងអវីចិនរកត្រូវគ្នាដូចពណ៌នាតទៅនេះគឺ :

កាលព្រះគោកាលិកភិក្ខុស្លាប់មរណភាពហើយ ហើយទៅកើតក្នុងអវីចិនរក ទើបមានភិក្ខុមួយរូបទូលសួរព្រះសម្ពុទ្ធថា អាយុក្នុងអវីចិនរកនោះប៉ុន្មាន? ត្រាស់តបថា នឹងរាប់ថាប៉ុណ្ណោះប៉ុណ្ណោះ បានដោយក្រ ប្រៀបដូចរាប់គ្រាប់ល្ងទាំងរទេះ ហើយទ្រង់សំដែងជាឧបមាណអាយុក្នុងអវីចិនរកនោះ ត្រូវរាប់ដូចតទៅនេះគឺ ១០លានជាកោដិ, ១០កោដិជាបកោដិ ១០បកោដិជាកោដិបកោដិ, ១០កោដិបកោដិជានហុត ១០នហុតជានិន្នហុត, ១០និន្នហុតជាអព្វុទ ២០អព្វុទៈជានិរព្វុទៈ ២០និរព្វុទៈជាអពពៈ ២០អពពៈជាអហហៈ ២០អហហៈជាអដដៈ ២០អដដៈជាកុមុទៈ ២០កុមុទៈជាសោគន្ធិកៈ ២០សោគន្ធិកៈជាឧប្បលៈ ២០ឧប្បលៈជាបុណ្ឌរិកៈ

២០ បុណ្ឌរិកៈ ជាបទុមៈ ១បទុមៈ ទើបជាកំណត់អាយុក្នុងអវីចិនរកនោះ ។

បាបកម្មដែលនាំឲ្យធ្លាក់នរកនេះ បានដល់អាចិណ្ណកម្មគឺការសន្សំធ្វើអំពើអាក្រក់ជានិច្ច បានដល់ការសម្លាប់សត្វ បំបាត់លួចប្លន់ទ្រព្យគេ ប្រព្រឹត្តការមេសុមិច្ឆាចារ ពោលពាក្យបោក ផឹកស្រាមេរ័យ ណាមួយជានិច្ចជានិរន្តរ៍មិនឈប់ឈរ ច្បាំងដណ្តើមយកស្រុកនគរគេខ្លះ ទម្លាយលោកអ្នកមានសីល សមាធិ បញ្ញាខ្លះ ទម្លាយព្រះអរិយៈខ្លះ ធ្វើអនន្តរិយកម្មខ្លះ ។

កាលរួចចាកនរកនេះហើយ នៅមិនទាន់អស់បាបកម្មក៏ត្រូវទៅធ្លាក់នរកជាបរិវារនឹងកើតជាប្រេត អសុរកាយ តិរច្ឆាន ត្រូវអត់ឃ្លានត្រូវជាប ក្រដួស គេវាយគេធាក់ គេចំម គេជះគេកាប់សម្លាប់សំឡេះ គេក្រៀវ ពន្ទះពន្ទាត់ ពង្រាត់បង្រាស ឲ្យព្រាសឲ្យព្រាត់ឲ្យរងឲ្យលុនឲ្យលូន ឲ្យស្លូនទ្យាកសរ៉ៈប៉ានទុក្ខពាល់ស្លាប់ ។ កាលរួចចាកអបាយទាំងនេះហើយ បើនៅមិនទាន់អស់បាបកម្ម ក៏មកកើតជាមនុស្សនរក មនុស្សប្រេត មនុស្ស អសុរកាយទៀត ។

៣-គូថនរកៈ គូថនរកនេះប្រែថា "នរកគូថ" គឺនរកជុំលាមក ។

អធិប្បាយថា នរកនេះបើវាស់ទទឹងនិងបណ្តោយបាន ១០០ យោជន៍ពេញ

ទៅដោយទឹកមូត្រនឹងដុំឈាមក ស្អុយគំរក់ឆ្អេះឆ្អាប អសោចិ៍នេកពេក ណាស់ ពេញទៅដោយហ្វូងដង្កូវដែលមានខ្លួនធំៗ ប៉ុនដំរីសារខ្លះ ប៉ុនទូក កញ្ច្រោលខ្លះ មានមាត់ស្រួចដូចម្ជុល ។ កាលពួកសត្វនរកត្រូវនាយនិរយបាលចាប់បោះចុះទៅក្នុងរណ្តៅនរកដែលមានដុំឈាមកអណ្តែតរពោង លាយឡំទៅដោយទឹកមូត្រដ៏ស្អោរនេះហើយ ពពួកហ្វូងដង្កូវក៏នាំគ្នាទៅ ចោះចាក់កស្បែកនិងសាច់ ឲ្យដាច់រលេះរលុះ ធ្លុះធ្លាយរហូតដល់ពោះ វៀនពោះតាំង ធ្វើឲ្យសត្វនរកលំបាកហ៉ាកយ៉ាប់ខ្ទាំង ដោយស្រេកឃ្លាន និងឈឺចាប់ ស្អុយឡប់ឆប់ស្លុទតែលាមក, កាលសេចក្តីស្រេកឃ្លានកើត មានឡើងហើយក៏នាំគ្នារើសដុំឈាមក យកបកទាំងទំពាស៊ីជួសអាហារមាន

គាថាបញ្ជាក់ថា

រហទោ អយមុត្តករីសបូរោ
ទុគ្គន្ធរូបោ អសុចិ បូតិ វាយតិ
ខុទាបរេតា មនុជា អទន្តិ

ប្រែថា នរកនេះ ពេញទៅដោយមូត្រគូថ មានក្លិនស្អុយអសោចិ៍ ពេកណាស់ ពពួកសត្វនរកដែលអត់ទ្រាំសេចក្តីស្រេកឃ្លានមិនបាន ក៏ រើសដុំឈាមកនិងទឹកមូត្រផឹកស៊ីជួសអាហារ ។

គម្ពីរអដ្ឋកថា ថា សត្វក្នុងនរកនេះ មានសេចក្ដីស្រេកឃ្លានខ្លាំងក្រៃណាស់ ពិបាកនឹងអត់ទ្រាំក៏នាំគ្នាដើរស៊ីលាមក ដែលក្ដៅដូចរងើកភ្លើងមកបេះជាដុំៗ ហើយស៊ីទៅ ។

កាលស៊ីចូលដល់ពោះពេលណា ក៏ក្ដៅស្អុកពោះវៀនស្លាប់ៗ ហើយកើតៗហើយស្លាប់ យ៉ាងដាប់មួយរំពេចភ្លាមៗ ក្នុងនរកនោះឯង នឹងខំប្រឹងប្រែងប្រវេប្រវាឡើងមកលើ ក៏ត្រូវនាយនិរយបាលដែលឈរចាំនៅមាត់ច្រាំងចាក់ទម្លាក់ទៅទៀត ។

បាបកម្មដែលនាំឲ្យធ្លាក់នរកនេះ បានដល់លាភមច្ឆរិយៈ គឺសេចក្ដីកំណាញ់លាភសក្ការៈ បន្លំយកលាភសង្ឃខ្លះ យកលាភរបស់មនុស្សដទៃខ្លះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈខ្លះ ដាក់ទោសដល់អ្នកដែលមិនមានសេចក្ដីទោសខ្លះ ប្រទូស្តអ្នកដែលខ្លួនបានពឹងពាក់ពំនាក់អាស្រ័យខ្លះ មានគាថានិពន្ធទុកជាគោលថា:

យេកេចិមេ ការណិកា វិភាសិកា
បរេសំ វិហឹសាយ សតា និវិដ្ឋា
តេ លុទ្ទកម្មា បសវេត្វ បាបំ
មិត្តទ្ទុនោ មិឡ្ហមទេធិ ពាឡា ។

ប្រែថា ជនណា ជាអ្នកបន្តសេចក្តីទុក្ខ ប្រទូស្តចំពោះអ្នកដែលមានគុណមានមិត្រសំឡាញ់ជាដើម តាំងខ្លួនជាអ្នកបៀតបៀនអ្នកដទៃ ជននោះត្រូវបានស៊ីមូត្រគូថក្នុងនរកនេះ ។

ក្នុងអដ្ឋកថា កំចាយសេចក្តីត្រង់ពាក្យថា ប្រទូស្តអ្នកមានគុណមានមិត្រសំឡាញ់ជាដើមនោះ គឺបានស៊ីផឹកដេកអង្គុយនៅក្នុងផ្ទះរបស់បុគ្គលណា ហើយប្រទូស្តបុគ្គលនោះ ដោយការណាមួយមានលួចយកមាសប្រាក់ជាដើម បុគ្គលនោះរមែងទៅធ្លាក់ចុះក្នុងគូថនរក ស៊ីលាមកគឺគូថជាអាហារ រហូតអស់បាបកម្ម ។

៤- កុក្កុលនរក ប្រែថា « នរកផេះ » កំពស់ទទឹងនិងបណ្តោយបាន ១០០ យោជន៍ពេញទៅដោយផេះដ៏ក្តៅនិងរងើករភើងធំៗប្រមាណប៉ុនប្រាសាទក្រហមរលាលរន្តាលប្រាលឆ្អៅក្តៅពន់ពេកណាស់ ៗ ក៏ត្រូវនាយនិរយបាលដេញវាយដោយលំពែង ស្នូនិងដែកស្រួច ហើយបានត្រឡេកមើលឃើញកុក្កុលនរកនេះ ក៏នឹកស្មានថាជាវាលបុប្ផកទ្យាច់ សម្រាប់ក្រសាលសប្បាយ មានចិត្តត្រេកអរណាស់ នាំគ្នារត់ស្ទើរសំដៅទៅ លុះធ្លាក់ទៅដល់ទើបដឹងថាជាផេះដ៏ក្តៅ ក៏នាំគ្នាបម្រះបម្រែងកន្ត្រានលោតស្ទុះឡើងវិញ តែឡើងមិនរួច ធ្លាក់ចុះទៅក្នុងរណ្តៅដ៏ក្តៅក្រម៉ចន្ទុះ

រលួយរលេះត្រូវដែកក្តៅឆេះខ្ទេចខ្ទី ស្លាប់ហើយកើត ៗ ហើយស្លាប់ក្នុងទីនោះ រាប់រយ ៗ ពាន់ ៗ ដង ត្រូវទទួលទោសវេទនារហូតដល់អស់បាបកម្ម ។

បាបកម្មដែលនាំឲ្យធ្លាក់នរកនេះ បានដល់ការចាប់សត្វទាំងរស់ ព្រោះចុះទៅក្នុងរងើកភ្លើងខ្លះ ជាសមណៈខូចសីលបរិភោគបច្ច័យ ៤ របស់អ្នកស្រុកខ្លះកំណាញ់ធម៌មិនត្រូវការប្រាប់អ្នកដទៃខ្លាចគេចេះដឹងជាងខ្លួននឹងខ្លាចគេបានលាភយសជាងខ្លួនខ្លះ ។

៥- សិម្ពលិនរក ប្រែថា នរកដើមរកា មានទំហំដើមខ្ពស់ធំ ដើមមួយ ៗ កំពស់មួយយោជន៍ មានបន្លាវែង ១៦ អង្គុលី មានចុងស្រួចមុតយ៉ាងទីបំផុត ជាដើមការដែក ។ ពួកនាយនិរយបាលដេញឲ្យពួកសត្វនរកឡើងដើមរកា ដោយប្រើកន្ត្រាគឺការយកលំពែងស្និងដែកស្រួចជាគ្រឿងបណ្ដាប់ប្រាប់ឲ្យឡើង ក្នុងវេលាដែលពួកសត្វនរកឡើងទៅ បន្លារកាដែកក៏ក្លុងចុះមក បន្ទាប់នោះក៏មុតធ្លុះស្លុះសាយសព្វសាច់រលុះរលេះហូរឈាមសស្រាក់សស្រាក; រីឡើងទៅមិនរួច ក៏បែរមុខត្រឡប់ចុះមក បន្លារកាដែកក៏បះព្រាងឡើងលើវិញ ពួកនាយនិរយបាលក៏នាំគ្នាចាក់ដោយលំពែងឲ្យឡើងទៅទៀត កាលឡើងទៅដល់ចុងរកាហើយ ក៏មាន

ក្អែកត្មាតធំ ៗ ទំហំប៉ុនដំរីសារ មានចំពុះដាដែកពោរបកចឹកក្បាល កាលគេត្រាំមិនបាន ក៏នាំគ្នាប្រវេប្រវាចុះមក ក្នុងវេលាចុះមក បន្ទារគាក៏បះប្រាងឡើងលើ វេលាឡើងបន្ទារគាក៏ក្លុងចុះក្រោមទៀត ធាក់មុតកាងកាយសត្វនរកទាំងនោះឲ្យធ្លុះធ្លាយក្តៅក្រហាយ រំសាប់សល់ឈើចាប់ដានិរន្ត៍ពន់ពេកណាស់ ៗ កាលចុះដល់ផ្ទាល់ដី ក៏ត្រូវហ្វូងឆ្កែដែលមានខ្លួនធំ ៗ ប៉ុនដំរីសារ ត្របាក់ខាំសាច់ដាច់រយៈទាំងដុំ ៗ ទៀត ទាំងពួកនាយនិរយ-បាលក៏ដេញពួយដេញចាក់ឲ្យឡើងទៅទៀតឡើងចុះៗឡើងដើមរកាដែកស្រែកយំរងំដោយឈឺចាប់ មិនឈប់ឈរទាំងថ្ងៃទាំងយប់ទាំងព្រលប់ទាំងព្រលឹម តតសង្វៀមរកស្ងួនឈឺញាប់ញ័រចបនចសោះឡើយ ស្លាប់កើត ៗ ច្រើនកំណើត ដូចកំណត់កន្លងគេនោះ រហូតលុះត្រាតែអស់បាបកម្ម ៗ

ឲ្យបកម្មដែលឲ្យធ្លាក់រណ្តៅសិម្ពលីនេះ បានដល់ទោសកាមេសុ-មិច្ឆាចារ ការប្រព្រឹត្តកន្លងបវេណីនឹងប្រពន្ធកូនចៅអ្នកដទៃ និងជាស្រីកាឡកណ្ណីប្រព្រឹត្ត មានបាលីពុទ្ធភាសិតក្នុងសន្និបាតក ដែលបានដកស្រង់មកជាគ្រឿងសំអាងថា

ឯតេ សជន្តិ និរយេ តត្ត តិវិណាកណ្តកេ
នារិយោ ច អតិចារិនិយោ នរា ច បរទារគូ ៗ

តេ បតន្តិ អយោកូដា វិទ្ធា វិហតា បុថុ
សយន្តិ វិនិវិទ្ធង្គា ទីឃំ ជគ្គន្តិ សំវរី ។

ប្រែថា ស្រីប្រព្រឹត្តផិតក្រៅចិត្តស្វាមី និងប្រុសអប្រិយប្រព្រឹត្តខុសនឹងភរិយាអ្នកដទៃ (ទោសកំហុសនេះ) ត្រូវធ្លាក់សិម្ពលីនរកដែលពេញទៅដោយដើមរកា មានបន្លាដ៏ស្រួចមុតយ៉ាងបំផុត ឆេះជាអណ្តាតភ្លើង ។ សត្វនរកទាំងនោះ រមែងត្រូវនាយនិរយបាលចាក់ពួយដោយអាវុធ ហើយកាវត្តក់ពាញក្បាលឲ្យធ្លាក់ចុះចាកដើមរកាដែក នៅលើផែនដែកក្រហមឆ្អៅអស់រាត្រីដ៏យូរអង្វែង ។

៦-អសិបត្តនរក ប្រែថា "នរកស្លឹកដាវ" គឺក្នុងនរកនោះពេញទៅដោយឈើព្រៃធំមានមែក ស្លឹកត្រសុំត្រសាយសាខាស្យេនា មើលទៅសមជាទីសម្រាកឈប់ គួរជាម្លប់ត្រជាក់ស្រួលធ្វើឲ្យសត្វនរកដែលរត់រួចចាករណ្តៅសិម្ពលី ហើយឃើញថាជាទីសួនចំការស្វាយ ចូលចិត្តថានឹងបានក្សាន្តសប្បាយ ទើបនាំគ្នាខ្វល់ខ្វាយប្រញាប់រត់តម្រង់ទៅត្រាច់ចូលទៅដល់ក្នុងនរកនេះហើយ ក៏នាំគ្នាអង្គុយឈប់ក្រោមម្លប់ឈើនោះមួយសន្ទុះ ស្រាប់តែមានខ្យល់បក់បោកមកប៉ះពាល់ដាលដល់ស្លឹកឈើទាំងនោះឲ្យធ្លាក់ចុះមក ។ ស្លឹកឈើដែលធ្លាក់ចុះមកទាំងប៉ុន្មាន

ក៏ក្លាយទៅជាអាវុធមានមុខមុតយ៉ាងទីបំផុត គឺក្លាយទៅជាលំពែង ដាវ កាំបិត ព្រួញជាដើម ធ្លាក់មកប៉ះត្រូវសត្វនរកទាំងនោះ ប៉ះក្បាលដាច់ក្បាល ប៉ះត្រចៀកដាច់ត្រចៀក ប៉ះច្រមុះដាច់ច្រមុះ ប៉ះជើងដាច់ជើង ប៉ះដៃដាច់ដៃ ប៉ះអវយវៈណាក៏ដាច់អវយវៈនោះៗ ។

សត្វនរកពួកនោះ មានខ្លួនធ្លុះដាច់ដោច ជាកំណាត់តូចកំណាត់ធំ ខ្លះត្រូវខ្ទាំងក៏ស្លាប់ៗហើយកើតៗហើយស្លាប់ ត្រូវស្ទូកអាវុធកាប់កាត់ជាកំណាត់ៗ ។ ខ្លះខំរត់កខ្វល់កក្វាសទៅប្រទះដើមឈើខាងមុខទៀត ក្តួចតិកតីតាំងចូលទៅជ្រកទៀត ក៏ត្រូវស្ទូកឈើធ្លាក់មកជាអាវុធមុតធ្លុះដាច់ដូចមុនទៀត; បានទទួលទុក្ខសោយទោសរហូតដល់អស់បាបកម្ម ។

បាបកម្មដែលនាំឲ្យធ្លាក់នរកនេះ បានដល់ការបាញ់ ឬ ចាក់កាប់សម្លាប់សំឡេះគ្នាដោយអាវុធយុទ្ធភ័ណ្ឌផ្សេងៗ ។

៣ – ខារោទកនរក ៗ នេះ ជាស្ទឹងដែលពេញទៅដោយទឹកទង់ដែង ឆេះជាអណ្តាតភ្លើង សម្រាប់ប្រកមាតសត្វនរក ។

ខារោទកនរកនេះ ទីងហៅថាវេតរណីនរកក៏បាន ព្រោះក្នុងនរកនេះជាស្ទឹងដាស់ពាសទៅដោយដើមផ្តៅ ដែលមានបន្លាស្រួចដូចចុងលំពែង ឆេះជាអណ្តាតភ្លើង ។ ពួកសត្វនរកធ្លាក់ទៅក្នុងនរកនេះ អស់

ច្រើនពាន់ឆ្នាំ មានខ្លួនដាច់ជាកំណាត់តូចកំណាត់ធំ នៅលើបន្លាផ្ដៅដែលមុតយ៉ាងទីបំផុតដូចកាំបិតកោរ ឆេះជាអណ្ដាតភ្លើង ។ ក្រោមបន្លាផ្ដៅចុះទៅពេញទៅដោយចម្រូងដែក ឆេះជាអណ្ដាតភ្លើង ; ចម្រូងដែកមួយ ៗ ធំប៉ុនដើមត្នោត ។

ពួកសត្វនរកគ្រារួចចាកបន្លាផ្ដៅចុះទៅ ក៏ត្រូវចម្រូងដែកកៀកក្ដៀបជាប់នឹងចម្រូងដែកដូចជាគេក្ដៀបត្រីកអស់កាលដ៏យូរ ក្នុងខណៈដែលក្ដៀបជាប់នៅនោះ ចម្រូងដែកក៏ឆេះឡើង រាងកាយពួកសត្វនរកក៏ឆេះឡើងដែរ ។ គ្រារួចចាកចម្រូងដែកចុះទៅ ក៏ត្រូវស្លឹកឈូកដែកមុតឆេះជាអណ្ដាតភ្លើង ; សោយទុក្ខវេទនាអស់កាលដ៏យូរយារ ។ គ្រារួចចាកស្លឹកឈូកដែកក៏ធ្លាក់ចុះទៅក្នុងទឹកផ្សា ទឹកផ្សាក៏ឆេះឡើង សត្វនរកក៏ឆេះជុំវិញខ្លួន ; ក្រោមទឹកផ្សាចុះទៅពេញទៅដោយទឹកក្រែក ។ ពួកសត្វនរកគិតគ្នាថា "ខាងក្រោមនេះនឹងជាយ៉ាងណាហ្ន៎?" ទើបនាំគ្នាមុជចុះទៅ ក៏ត្រូវទឹកក្រែកមុតកាត់រាងកាយដាច់ជាកំណាត់តូចកំណាត់ធំ នាំគ្នាយំរអ៊ំទៅ ទើបនាំគ្នាហែលទៅវិញទៅមកតាមក្រសែទឹក ។ ចំណែកនាយនិរយបាល ដែលឈរចាំនៅមាត់ច្រាំង ក៏គាំងនាំគ្នាចាក់ដោយដែកស្រួច-លំពែង-ស្ន-ស្នាន ដូចជាគេចាក់គេសត្រី ។ ហើយទើបយកសន្ទូច

ដែកដ៏ធំ ស្នួចថ្ពក់ទាញទន់អួសឡើងមកដុតលើផ្ទាំងដែកក្រហមឆ្អៅ ក្តៅមហិមា ហើយឲ្យសត្វនរកហាមាត់យកដុំដែកនិងទឹកទង់ដែងច្រកទៅក្នុងមាត់ សោយទុក្ខវេទនាពន់ពេក រហូតដល់អស់បាបកម្ម ។

បាបកម្ម ដែលនាំឲ្យធ្លាក់នរកនេះ បានដល់ការឆបោកគេស៊ីខ្លះ សម្លាប់សត្វដោយការបោះចុះទៅក្នុងទឹកកំពុងក្តៅខ្លះ (ដូចស្ងោរអណ្តើក ស្ងោរហ៊ីង ស្ងោរខ្ចៅខ្យងតាំងរស់ជាដើម) ជាអ្នកប្រមឹកផឹកសុរាមេរ័យខ្លះ, បៀតបៀនវាយដំអ្នកដែលមានកំឡាំងតិចជាងខ្លួនខ្លះ, មាននិពន្ធគាថាពន្យល់ថា

យេ ទុព្ពលេ ពលវន្តោ ជីវលោកេ
ហឹសេន្តិ រោសេន្តិ សុបាបកម្មា
តេ លុទ្ទកម្មា បសវេត្វា បាបំ
តេមេ ជនា វេតរណឹ បតន្តិ ។

ប្រែថា បុគ្គលណាមានកំឡាំង ដែលជាមនុស្សមានចិត្តអាក្រក់ បៀតបៀនជេថាស្តីបន្ទោសគំរាមគំភេះ ចំពោះអ្នកដែលមានកំឡាំងតិចជាងខ្លួន បុគ្គលនោះឈ្មោះថា ធ្វើកម្មដ៏អាក្រក់រមែងបានជួបប្រទះបាប បុគ្គលនោះៗ រមែងធ្លាក់វេតរណីនរក ។

អធិប្បាយតាមអដ្ឋកថាថា ពាក្យថា មានកំឡាំង: បានដល់កំឡាំងកាយ កំឡាំងទ្រព្យ កំឡាំងអាជ្ញា ១ ពាក្យថា មានកំឡាំងតិច: គឺមានកម្លាំងទាំង៣នេះតិច ១ ពាក្យថា បៀតបៀន: សំដៅយកការគំហឹត គំហែងដោយអាការៈវាយដំច្រំដាក់ ១ ពាក្យថា គំរាមគំហោះ: បានដល់ការដេថាស្តីបញ្ចោរ ដោយពាក្យអសុរោះផ្សេងៗ ១

## អំពីវិធីសាកសួរទេវទូតនៃព្រះយមរាជ

បាបកម្ម ដែលនាំឲ្យធ្លាក់នរកទាំង ៧ ដូចបានរៀបរាប់រួចមកហើយ ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រកាសត្រាស់សំដែងទុកក្នុងទេវទូតសូត្រថា បានដល់ទុច្ចរិត ១០ ឬអកុសលកម្មបថ ១០ តែទ្រង់មិនបានសំដែងឲ្យស្តាប់ក្រឡាថា អ្នកធ្វើទុច្ចរិតឬអកុសលកម្មបថ ១០ ត្រូវតែធ្លាក់នរកតែម្យ៉ាងឡើយ, នឹងទ្រង់មិនបានបញ្ជាក់ទុកថា ទុច្ចរិត១ណា អកុសលកម្មបថ១ណា ឲ្យធ្លាកនរកណ្ដៅណា ដោយពិតប្រាកដទេ គ្រាន់តែទ្រង់សំដែងទុកជាកណ្តាលៗថា ជួនកាលពួកខ្លះ ក៏កើតជាប្រេត ពួកខ្លះក៏កើតជាតិរច្ឆាន ពួកខ្លះក៏ទៅកាន់សំណាក់ព្រះយមរាជ កាលព្រះយមរាជសាកសួរទេវទូតទាំង៥ហើយ ឃើញថាមិនបានធ្វើបុណ្យទុកបន្តិចខ្លះដែរតែនឹកមិនឃើញ ព្រះយមរាជក៏ទ្រង់គង់នៅស្ងៀមហើយ នាយនិរយបាល

ទើបនាំគ្នាចាប់ពួកនោះទៅដាក់ទោសក្នុងនរក ពួកនោះបានទទួលទុក្ខទោសនៅក្នុងនរកគ្រប់ទាំង ៧ ខ្លះត្រឹមតែរណ្ដៅណាមួយ ខ្លះធ្លាក់ទៅយូរ ខ្លះឆាប់ ខ្លះតាមសមគួរដល់បាបកម្ម ។

ចំណែកអ្នកដែលត្រូវទៅកាន់សំណាក់ព្រះយមរាជនោះ ព្រះសម្ពុទ្ធជាម្ចាស់ត្រាស់សំដែងទុកថា ពួកអ្នកដែលធ្វើទុច្ចរិតនោះ គ្រាស្លាប់ហើយ បើមិនបានទៅកើតជាប្រេត ឬ សត្វតិរច្ឆានទេ ក៏ទៅកើតក្នុងយមលោក។ ពួកនាយនិរយបាលបានឃើញហើយ ក៏នាំគ្នាចាប់យកទៅកាន់សំណាក់ព្រះយមរាជ ដើម្បីឲ្យទ្រង់ដាក់ទោស ទូលថា "អ្នកនេះកាលនៅជាមនុស្ស មិនបានប្រណិប័តន៍ មាតាបិតា សមណព្រាហ្មណ៍ មិនគោរពកោតខ្លាចអ្នកធំ ក្នុងត្រកូលរបស់ខ្លួន នឹងមិនគោរពកោតខ្លាចមនុស្សព្រឹទ្ធាចារ្យ; សូមព្រះអង្គទ្រង់ដាក់ទោសចុះ" ។

មុននឹងដាក់ទោសព្រះយមរាជបានសាកសួរទេវទូតទាំង ៥ គឺ ក្មេងតូច ១ មនុស្សចាស់ ១ មនុស្សឈឺ ១ អ្នកទោស ១ មនុស្សស្លាប់ ១ ទ្រង់ត្រាស់សួរទេវទូតទី ១ ជាដំបូងថា ម្នាលបុរស កាលអ្នកនៅក្នុងមនុស្សលោក បានឃើញទេវទូតទី ១ ឬទេ ? បើគេតបថា មិនបានឃើញ, ទើបសួរទៅថា អ្នកមិនធ្លាប់ឃើញក្មេងតូចដែលដេកផ្ងារ ប្រឡាក់

ដោយមុខក្រនិងគូថនៅលើអង្រឹងខ្លះឬទេ? កាលអ្នកនោះទូលតបថា បាន ឃើញ, ទើបត្រាស់សួរគេទៅថា កាលអ្នកបានឃើញហើយ បានគិតថា យើងមានសេចក្តីកើតជាធម្មតា មិនគង់រួចសេចក្តីកើតទៅបាន យើងត្រូវ ធ្វើអំពើល្អទុកដោយកាយវាចាចិត្ត; តើអ្នកបានគិតដូច្នេះដែរឬ? កាល គេតបថា មិនបានគិត ទើបត្រាស់ថា អ្នកឯងប្រមាទហើយដែលមិនបាន ធ្វើសុចរិតដោយកាយ វាចា ចិត្ត ធ្វើតែទុច្ចរិតបាប សេចក្តីអាក្រក់របស់អ្នក នោះ មិនមែនមាតាបិតាធ្វើឲ្យ មិនមែនបងប្អូនមីងមាប្រុសស្រីណាធ្វើឲ្យ មិនមែនអាមាត្យញាតិសាច់សាលោហិតមិត្រសំឡាញ់ និងសមណៈព្រា-ហ្មណ៍ឬទេវតាណាធ្វើឲ្យទេ អ្នកធ្វើខ្លួនឯង នឹងត្រូវទទួលផល ដែល សេចក្តីអាក្រក់ខ្លួនឯង ។

គ្រាកាលព្រះយមរាជសាកសួរទេវទូតទី ១ ស្រេចហើយ ទើបសួរ ទេវទូតទី ២ តទៅថា កាលអ្នកនៅក្នុងមនុស្សលោកបានឃើញទេវទូត ទី ២ ដែរឬ? ។ បើគេទូលតបថា មិនបានឃើញ ទើបត្រាស់ថា អ្នកមិន ធ្លាប់បានឃើញមនុស្សចាស់ខ្លះទេឬ? បើគេតបថា ធ្លាប់បានឃើញ ក៏ សួរគេទៅទៀតថា ចុះកាលបានឃើញហើយ អ្នកបានគិតថា យើងមាន សេចក្តីចាស់ជាធម្មតា មិនគង់រួចពីសេចក្តីចាស់ទៅបាន នឹងត្រូវប្រឹង

ប្រព្រឹត្តសុចរិតដោយកាយ វាចា ចិត្តទេឬ។ កាលគេទូលតបថា មិនបានគិត ។ ទើបត្រាស់ថា អ្នកធ្វេសប្រហែសហើយ ដែលមិនបានប្រព្រឹត្តសុចរិតដោយកាយ វាចា ចិត្ត ប្រព្រឹត្តធ្វើតែសេចក្តីអាក្រក់ ។ល។

គ្រាកាលព្រះយមរាជសាកសួរទេវទូតទី ២ចប់ហើយ ទើបសួរទេវទូតទី ៣ តទៅថា កាលអ្នកនៅក្នុងមនុស្សលោកដែលបានឃើញមនុស្សឈឺដែរឬ។ ៗ កាលទូលតបថា បានឃើញ ។ ទើបទ្រង់ត្រាស់សួរថា កាលបានឃើញហើយអ្នកបានគិតថា យើងតែងមានដម្ងឺឈឺចាប់ជាធម្មតា មិនគួនរួចសេចក្តីឈឺចាប់ទៅបាន យើងត្រូវធ្វើសេចក្តីល្អដោយកាយ វាចា ចិត្ត តើអ្នកបានគិតយ៉ាងនេះទេឬ។ កាលទូលតបថាមិនបានគិត ។ ទើបត្រាស់ថា អ្នកឯងប្រមាទហើយ ។ល។

កាលព្រះយមរាជ សាកសួរទេវទូតទី ៣ ចប់ហើយ ទើបត្រាស់សួរទេវទូតទី ៤ តទៅថា កាលអ្នកនៅក្នុងមនុស្សលោក បានឃើញអ្នកទោស ដែលត្រូវគេចាប់ចងដាក់ខ្នោះឃ្នាងណាំងគុកប្រវាក់ គេវាយដំប្រំដាក់ទីងកាត់ក្បាលខ្លះទេឬ។ កាលទូលតបថា បានឃើញ ។ ទើបត្រាស់សួរថា កាលអ្នកឃើញហើយ តើអ្នកបានគិតថា ពួកនេះបានធ្វើអំពើអាក្រក់ទុច្ចរិត ទើបត្រូវទទួលទោសទុក្ខផ្សេង ៗ ក្នុងជាតិបច្ចុប្បន្ន

ទាន់ភ្នែកឃើញច្បាស់លាស់ មិនបាច់និយាយដល់ជាតិខាងមុខឡើយ យើងត្រូវធ្វើអំពើល្អដោយត្រៀមទុក យ៉ាងនេះឬទេ ។ កាលគេទូលតបថាមិនបាន គិត ។ ទើបត្រាស់ថា អ្នកឯងប្រមាទហើយ ។ល។

កាលព្រះយមរាជ សាកសួរទេវទូតទី៤ចប់ហើយ ទើបត្រាស់សួរទេវទូតទី ៥ តទៅថា កាលអ្នកជាមនុស្សនៅក្នុងមនុស្សលោកបានឃើញទេវទូតទី ៥ ឬទេ។ កាលទូលតបថា មិនបានឃើញ ទើបត្រាស់សួរថា អ្នកដែលបានឃើញមនុស្សស្លាប់ទេឬ។ កាលទូលតបថា បានឃើញ ។ ទើបត្រាស់សួរថា កាលអ្នកបានឃើញហើយ តើបានគិតយ៉ាងនេះទេឬថា យើងមានសេចក្ដីស្លាប់ជាធម្មតា មិនរំលងកន្លងរួចផុតចាកសេចក្ដីស្លាប់ទៅបានឡើយ យើងត្រូវប្រព្រឹត្តសុចរិតទុកដោយកាយ វាចា ចិត្ត ។ កាលទូលតបថា មិនបានគិត ។ ទើបត្រាស់ថា អ្នកឯងប្រមាទហើយ ដែលព្រងើយកន្តើយប្រហែសធ្វេស មិនបានធ្វើល្អដោយកាយវាចាចិត្ត ប្រព្រឹត្តធ្វើតែសេចក្ដីអាក្រក់សេចក្ដីអាក្រក់របស់អ្នកនោះមិនមែនមាតាបិតាធ្វើឲ្យ មិនមែនបងប្អូនប្រុសស្រីណាធ្វើឲ្យ មិនមែនអាមាត្យញាតិជាតិសាច់សាលោហិតមិត្រសំឡាញ់សមណព្រាហ្មណ៍ឬទេវតាណាធ្វើឲ្យទេ អ្នកធ្វើខ្លួនឯង ត្រូវទទួលផលរបស់សេចក្ដីអាក្រក់ដោយខ្លួនឯងចុះ ។

គ្រាកាលព្រះយមរាជសាកសួរទេវទូតទាំង ៥ នេះចប់ហើយ ក៏ទ្រង់គង់នៅស្ងៀម ។ ពួកនាយនិរយបាលទើបនាំគ្នាចូលទៅចាប់អ្នកនោះនាំទៅធ្វើទោស ដូចបានសំដែងរួចមកហើយ ។

## អ្នកដែលទៅកាន់សំណាក់ព្រះយមរាជ

ក្នុងអដ្ឋកថានៃទេវទូតសូត្រ ព្រះអដ្ឋកថាចារ្យតាំងបញ្ហានិងវិសជ្ជនាទុកដូចតទៅនេះថា "នរណាត្រូវព្រះយមរាជសួរទេវទូត? នរណាដែលមិនត្រូវព្រះយមរាជសាកសួរ? វិសជ្ជនាថា នរណាធ្វើបាបទុកច្រើន នរនោះត្រូវទៅកាន់នរកតែម្តង នរណាធ្វើបាបទុកតិច នរនោះត្រូវសាកសួរ ប្រៀបដូចចោរដែលគេចាប់របស់សំគាល់បាន មានឡាក់ឋានល្មមហើយ មិនបាច់វិនិច្ឆ័យក្នុងរាជសាលាទៀតទេ គេកាត់ទោសធ្វើទុក្ខតែម្តង បើចាប់របស់សំគាល់មិនបាន តាំងឡាក់ឋានមិនល្មមសមគួរ ទើបត្រូវវិនិច្ឆ័យជាមុន ។ ចំណែកអ្នកដែលធ្វើបាបទុកតិចនឹងធ្វើបុណ្យទុកខ្លះ កាលទៅកាន់សំណាក់ព្រះយមរាជ ជួនកាលព្រះយមរាជមិនទាន់សាកសួរទេវទូតផង ក៏រលឹកនឹកឃើញដល់បុណ្យដែលខ្លួនបានធ្វើទុកដោយខ្លួនឯងខ្លះក៏មាន ខ្លះនោះលុះតែព្រះយមរាជសាកសួរទេវទូត ទើបរលឹកនឹកឃើញក៏មាន ដូចនិទានតទៅនេះ ៖

ដំណាលថា មានទមិឡម្នាក់ឈ្មោះទីឃទន្តទមិឡ១នោះ បានបូជាព្រះចេតិយក្នុងសមណគិរីវិហារដោយសំពត់មួយផ្ទាំង លុះស្លាប់ហើយបានទៅកើតក្នុងទីដិតកុស្សនរកដោយបាបកម្មដែលខ្លួនធ្វើទុក, កាលឃើញអណ្តាតភ្លើង ក៏នឹកឃើញដល់សំពត់ដែលខ្លួនបានបូជាព្រះចេតិយហើយបានត្រឡប់ឡើងទៅកើតក្នុងស្ថានសួគ៌ ។

មានម្នាក់ទៀត បានប្រគេនសំពត់ដល់ភិក្ខុកំឡោះ ដែលជាបុត្ររបស់ខ្លួន ក្នុងវេលាហៀបទៀបនឹងស្លាប់មាននិមិត្តកើតឡើងក្នុងចិត្តថា «សំពត់ៗ» គ្រាស្លាប់ហើយបានទៅកើតក្នុងទីដិតកុស្សនរក កាលនឹកឃើញដល់សំពត់ដែលខ្លួនបានថ្វាយនោះ ក៏បានត្រឡប់ឡើងទៅកើតក្នុងស្ថានសួគ៌ ។

ក៏អ្នកដែលត្រូវព្រះយមរាជសាកសួរទេវទូតនោះ ជនខ្លះក៏រលឹកនឹកឃើញដល់បុណ្យ ក្នុងវេលាដែលទេវទូតទី១ខ្លះ ជនខ្លះក៏រលឹកនឹកឃើញដល់បុណ្យ ក្នុងវេលាសួរទេវទូតទី២, ខ្លះទី៣ ខ្លះទី៤ ខ្លះទី៥ ។ ជនខ្លះកាលសាកសួរទេវទូតគ្រប់ទាំង៥ហើយ រលឹកនឹកបុណ្យមិនឃើញក៏មានព្រះយមរាជត្រូវឲ្យសតិដល់ជននោះដូចអាមាត្យម្នាក់ ដែលបានបូជាព្រះចេតិយដោយផ្កាម្លិះ ហើយផ្សាយចែកចំណែកបុណ្យដល់ព្រះយមរាជ

លុះស្លាប់ហើយបានទៅកើតក្នុងទីជិតឧស្សុទនរក ត្រូវនាយនិរយបាលនាំទៅកាន់សំណាក់ព្រះយមរាជ ។ សាកសួរទេវទូតទាំង ៥ ចប់ហើយ ក៏រលឹកនឹកដល់បុណ្យមិនឃើញ ព្រះយមរាជទើបឲ្យសតិថា "អ្នកបានបូជាមហាចេតិយដោយផ្កាម្លិះ ហើយបានផ្សាយចំណែកបុណ្យដល់យើងមិនមែនឬទេ ? " ។ កាលព្រះយមរាជបានឲ្យសតិយ៉ាងនេះ គេក៏នឹកឃើញហើយបានទៅកើតស្ថានសួគ៌ ។

បើនរណារលឹកបុណ្យមិនឃើញ កាលព្រះយមរាជពិចារណាឃើញថា អ្នកនោះមិនបានធ្វើបុណ្យអ្វីមួយទុកទេ ក៏ទ្រង់នឹងនៅស្ងៀមដោយត្រិះរិះថា "ទុក្ខធំនឹងមានដល់គេ" ។

កាលបើព្រះយមរាជគង់ស្ងៀមយ៉ាងនេះហើយ ពួកនាយនិរយបាលក៏នាំគ្នាចូលទៅចាប់ចងជនទាំងនោះដោយចំណង ៥ ប្រការ គឺដាក់ប្រដាក់ដែកគ្រងដៃទាំងពីរនិងជើងទាំងពីរនិងកណ្ដាលខ្លួន ហើយអូសទាញយកទៅខ្លះ ចងព្យួរដោយយកជើងឡើងលើ យកក្បាលសំយុងចុះក្រោមខ្លះ នាំយកទៅឲ្យដេកក្រដាងនៅលើផែនដែកក្រហមខ្លះ ដេញឲ្យឡើងដេញឲ្យចុះតាមភ្នំដែលឆេះជាអណ្ដាតភ្លើងខ្លះ ចាប់បោះចុះទៅក្នុងខ្ទះលោហកុម្ភី គឺខ្ទះទង់ដែង ដែលពេញពោរទឹកពុះទៅដោយទឹកទង់ដែងដ៏ក្ដៅខ្លះ ។

# អំពីព្រះយមរាជនិងនាយនិរយបាល

ពាក្យថា "ព្រះយមរាជ" ដូចបានដំណាលមកហើយ ក្នុងទេវទូតសូត្រ ព្រះពុទ្ធជាម្ចាស់មិនបានត្រាស់សំដែងទុកថា បានដល់បុគ្គលណាទេ, តែក្នុងអដ្ឋកថាព្រះអដ្ឋកថាចារ្យបានសំដែងទុកថា ព្រះយមរាជនោះបានដល់ "ព្រះបាទវេមានិកប្រេត" គឺស្ដេចប្រេតដែលមានវិមាននៅ; ដោយអធិប្បាយថា ព្រះយមរាជនោះ ពេលខ្លះក៏បានសោយទិព្វសម្បត្តិ មានដើមព្រឹក្សាជាទិព្វ មានស្រីស្នំជាទិព្វជាដើម នៅក្នុងទិព្វវិមាន, ពេលខ្លះក៏បានទទួលទុក្ខ ។ ព្រះយមរាជនោះ មិនមែនមានតែមួយអង្គទេ មានដល់ ៤ អង្គ ប្រចាំនៅទ្វារទាំង ៤ របស់នរកធំ ទ្វារមួយ ១ អង្គ ។

ឯពាក្យថា "នាយនិរយបាល" ក្នុងទេវទូតសូត្រនិងអដ្ឋកថាមិនមានពន្យល់ទេ មានតែពោលថា "នាយនិរយបាលៗ ប៉ុណ្ណោះ មិនបានបញ្ជាក់ថាបានដល់បុគ្គលណា, តែបើពិនិត្យតាមរូបសព្ទថា "និរយបាល" ដែលប្រែថា "អ្នករក្សានរក" និងពិនិត្យតាមពាក្យរបស់ព្រះអដ្ឋកថាចារ្យថា "ក្នុងមនុស្សលោកមានការដាក់ពេសនឹងអ្នកធ្វើទោសយ៉ាងណា ក្នុងនរកក៏មាននាយនិរយបាលយ៉ាងនោះដែរ" ដូច្នេះក៏ឃើញបាន

ថា នាយនិរយបាលនោះ បានដល់អ្នកត្រួតត្រាសត្វនរក សម្រាប់ដាក់ទោសធ្វើទុក្ខសត្វនរកនោះឯង ។

ក៏ "នាយនិរយបាល" នេះ បានដល់បុគ្គលដែលមិនបានធ្វើបាប ថែមទាំងមិនបានធ្វើបុណ្យណាមួយទុកក្នុងមនុស្សលោក តែកាលឃើញអ្នកដទៃធ្វើបាប ដូចឃើញគេសម្លាប់សត្វជាដើម ហើយត្រេកអរតាមបុគ្គលនោះលុះស្លាប់ រមែងតែងបានទៅកើតជានាយនិរយបាល ។

## គាថាទីបំផុតនៃទេវទូតសូត្រ

ចោទិតា ទេវទូតេហិ យេ បមជ្ជន្តិ មាណវា
តេ ទីឃរត្តំ សោចន្តិ ហីនកាយុបគា នរា
យេ ច ខោ ទេវទូតេហិ សន្តោ សប្បុរិសា ឥធ
ចោទិតា នប្បមជ្ជន្តិ អរិយធម្មេ កុទាចនំ
ឧបាទានេ ភយំ ទិស្វា ជាតិមរណសម្ភវេ
អនុបាទា វិមុច្ចន្តិ ជាតិមរណសង្ខយេ
តេ ខេមបត្តា សុខិនោ ទិដ្ឋធម្មាភិនិព្វុតា
សព្វេរភយាតីតា សព្វទុក្ខំ ឧបច្ចគុន្តិ ។

ប្រែថា បុគ្គលណា ត្រូវទេវទូតទាំងឡាយដាស់តឿនហើយ នៅតែប្រមាថ បុគ្គលនោះ នឹងចូលទៅដល់កំណើតកើតក្នុងឋានអាក្រក់ ថោកទាបគឺកើតក្នុងនរកត្រូវទទួលទុក្ខសោកនៅអស់រាត្រីកាលដ៏យូរ ។

ចំណែកបុគ្គលណា ដែលជាមនុស្សល្អ ត្រូវទេវទូតទាំងឡាយដាស់តឿនហើយ រមែងមិនប្រមាទក្នុងអរិយធម៌ បានដល់សីល ៥ គឺ មានសីល ៥ ប្រចាំនៅក្នុងខ្លួនជានិច្ច ។

បុគ្គលណា ឃើញភ័យក្នុងឧបាទាន ដែលជាគ្រឿងបន្តឲ្យមាន ជាតិ ជរា មរណៈ បុគ្គលនោះ រមែងរួចចាកឧបាទាន ព្រោះព្យាយាមផ្ដិ[illegible]របស់ ជាតិ ជរា មរណៈ ។

បុគ្គលនោះ បានឈ្មោះហៅថា ជាអ្នកមានសេចក្ដីសុខក្សេម ជាអ្នកបានសម្រេចនិព្វានក្នុងបច្ចុប្បន្នជាតិនេះ ជាអ្នកមិនមានពៀរ មិនមានភ័យ ជាអ្នកកន្លងផុតទុក្ខទាំងពួងទៅបានហើយ ។

## រួមនរកក្នុងទេវទូតសូត្រ

រួមនរក[illegible] ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សំដែងទុកក្នុងទេវទូតសូត្រមាន [illegible] នរក ២ អវិចិនរក ៣ គូថនរក ៤ កុក្កុ[illegible] នរក ៧ ខារោទកនរក ។

បណ្ដានរកទាំង ៧ អវិចិជានរកធំ, ៦ ទៀតជានរកតូចជាបរិវាររបស់អវិចនរក ។ អវិចិនរកកាស់ទទឹងនិងបណ្ដោយបាន ៩០០ យោជន៍ នរក ៦ ទៀតនោះ កាស់ទទឹងនិងបណ្ដោយបាន ១០០ យោជន៍ប៉ុនគ្នា ។

## និគមភាសិត

មួយនរកលោហកុម្ភី ទីពីរនរកអវីចិ
គូថនរកជាទីបី ទីបួននោះនៃឈ្មោះកុក្កុលៈ ។
ទីប្រាំនរកសិម្ពលី ទីប្រាំមួយអសិបត្ត
ទីប្រាំពីរខារោទក រួមជាសត្តៈនរកណា ។
ដកស្រង់ពីក្នុងច្បាប់ព្រះសូត្រ ឈ្មោះទេវទូតអដ្ឋកថា
រៀបចំផ្សំប្រូលលាយវោហារ សង្ខិតកថាប៉ុណ្ណោះហោង ។

ចប់នរកក្នុងទេវទូតសូត្រតែប៉ុណ្ណោះ

# និរយកថា

( តាមនេមិរាជជាតក )

## នមត្ថុ សុគតស្ស

ក្នុងនេមិរាជជាតក មានសេចក្តីដំណាលថា កាលដែលព្រះមុនីសម្ពុទ្ធរបស់យើងទាំងឡាយ បានសោយព្រះជាតិជាព្រះបាទនេមិរាជក្នុងក្រុងមិថិលា ក្សត្រាបានទ្រង់តាំងនៅក្នុងសីលធម៌ដ៏ល្អ ទាំងទ្រង់ដឹកនាំប្រុសស្រីជានិករបរិស័ទ ឲ្យប្រតិបត្តិប្រព្រឹត្តតាមព្រះអង្គផង, ប្រជារាស្ត្រគ្រប់ពួកគ្រប់ក្រុមទាំងនោះ ដែលបានប្រព្រឹត្តតាមពាក្យប្រៀនប្រដៅរបស់ព្រះអង្គ កាលលះបង់អាយុជីវិតមុនព្រះអង្គទៅ ក៏បានទៅឧប្បត្តិកើតក្នុងស្ថានកើតតាវត្តិង្សទេវលោកជាច្រើនគ្នា , ហើយបានពណ៌នាសរសើរគុណរបស់ព្រះអង្គ ក្នុងទីប្រជុំសមាគមទេវតាជាន់តាវត្តិង្សរឿយៗ របស់ដល់ព្រះឥន្ទ្រកោសិយ ទ្រង់មានព្រះហឫទ័យចង់ទស្សនានឹងទ្រង់ត្រាប់ការប្រាថ្នាស្តាប់ធម៌ របស់ព្រះបាទនេមិរាជ ទើបទ្រង់មានទេវបញ្ជាបង្គាប់ប្រើឲ្យមាតលីទេពសារថី នាំយកវេជយន្តរថចុះមកអញ្ជើញព្រះបាទនេមិរាជឲ្យស្តេចយាងទៅតាវត្តិង្ស ។

ក្នុងខណៈដែលព្រះបាទនេមិរាជ គង់វេជយន្តរថយាត្រាចេញចាក

ព្រះនគរទៅនោះ ទ្រង់មានព្រះរាជបំណងបង្ហាញទស្សនាការឋាននរក ទើបត្រាស់ឲ្យមាតលីទេពសារថី បែររថចុះទៅផ្លូវបាតាល ដំណាលសំដែងរឿងនរកថ្វាយព្រះអង្គឲ្យទ្រង់ជ្រាប តាមសមគួរដល់សមត្ថភាពព្រោកដកូនគម្ពីរដូចតទៅនេះ

១ – វេតរណីនទីនរកៈ នរកស្ទឹងបន្លាដែក (អធិប្បាយរួមហើយ)។

២ – សុនខនរកៈ នរកសុនខ គឺនរកដែលពេញទៅដោយឆ្កែ ផ្សេង ៗ មានគាថាសំអាងថាៈ

សាមា ច សោណា សពលា ច គិជ្ឈា
កាកោលសង្ឃា ច អទេន្តិ ភេរវា ។

ប្រែថា " ក្នុងនរកនេះ ពេញទៅដោយឆ្កែផ្សេង ៗ ក្រហមខ្លះ ពពាលខ្លះ មានតាំងហ្វូងត្មាតតាដក់ មានខ្លួនធំៗគួរខ្លាច " ។

## អធិប្បាយតាមអដ្ឋកថា ថាៈ

ឆ្កែទាំងនោះ មានខ្លួនធំ ៗ ប៉ុនដំរីសារ សម្រាប់ទាំត្របាក់ ពួកនរក និងពួកសត្វក្នុងនរកនេះ មានរាងកាយកំពស់ ៣ គាវុត គឺសិន . កាលពួកឆ្កែដេញទាន់ហើយ ក៏ត្របាក់ទាំឲ្យដួលចុះលើផែនដែកក្រហម យកជើងមុខទាំងពីរឡើងជាន់ចំដើមទ្រូង ទាំត្រ

បាក់សាច់ទាល់តែអស់ នៅសេសសល់តែឆ្អឹង ៗ ពួកត្មាតតាងសីងតែមានខ្លួនធំៗ ប៉ុនផ្ទះរទេះ មានចំពុះជាដែក តែងចឹកហែកស៊ីសត្វក្នុងនរកនេះ ៗ

បាបកម្មដែលនាំឲ្យធ្លាក់នរកនេះ លោកសំដែងទុកត្រឹមពីរយ៉ាង គឺសេចក្តីកំណាញ់នឹងការជេរស្តីសមណព្រាហ្មណ៍ មានគាថាបញ្ជាក់ទុកមកថា :

យេ កេចិមេ មច្ឆរិនោ កទរិយា
បរិភាសកា សមណព្រាហ្មណានំ
ហឹសេន្តិ រោសេន្តិ សុបាបធម្មា
តេលុទ្ទកម្មា បសវេត្វ បាបំ
តេ មេ ជនេ កាកោលុ សង្ឃា អទេន្តិ ។

ប្រែថា "បុគ្គលណាមានសេចក្តីកំណាញ់នឹងហាមប្រាមគេមិនឲ្យធ្វើទាន នឹងជេរស្តីបៀតបៀនគំរាមគំហោះ សមណព្រាហ្មណ៍ បុគ្គលពួកនោះឈ្មោះថាធ្វើកម្មដ៏អាក្រក់ ត្រូវធ្លាក់នរកនេះ ត្រូវពួកក្អែកត្មាតនិងតាដក់ចឹកកាន់កាយ ៗ

៣— អយបឋវីនរក: នរកផែនដីដែកក្រហម គឺនរកដែលមានផែនដីជាដែកក្រហម ប្រមាណ ៩ យោជន៍ ពួកសត្វនរកនេះត្រូវពួកនាយនិរយបាលវាយដោយអន្លូវដែកក្រហម ចុំនដើមក្លោកឲ្យដួល ផះ ហើយសំពងដោយញញួរដែកថែមទៀតរហូតដល់ល្អិតល្អន់ថែករូបខ្ចី មានគាថានិពន្ធថា:

សញ្ជោតិភូតា បថវី កមន្តិ
តត្ថេហិ ខន្ធេហិ ច បោថិយន្តិ ។

ប្រែថា "ពពួកសត្វកើតនរកនេះ ជាអ្នកមានរាងកាយអណ្តែតឡើងដើរទៅតាមផែនដី ត្រូវពួកនាយនិរយបាលសំពងដោយញញួរដ៏ក្តៅ" ។

បាបកម្មដែលនាំឲ្យធ្លាក់នរកនេះ លោកពោលទុកត្រឹមការបៀតបៀននឹងគម្រាមគម្រោះ មានគាថាសំគាល់ថា

យេ ចរលោកស្មឹ សុបាបធម្មិនោ
នរញ្ច នារិញ្ច អបាបធម្មំ
ហឹសេន្តិ រោសេន្តិ សុបាបធម្មា
តេ លុទ្ទកម្មា បសវេត្វ បាបំ

តេមេ ជិតា ខន្ធហតា សយន្តិ ។

ប្រែថា " នរជនឯណា ក្នុងជីវលោកនេះ ជាអ្នកមានចិត្តអាក្រក់ បៀតបៀន គ្រគោះគម្រាមគម្រោះជេរស្តីនូវនរជនជាតិប្រុសស្រី ដែលមិនមានសេចក្តីខុស ជនដែលធ្វើកម្មដ៏អាក្រក់ទាំងនោះ លុះធ្វើសេចក្តីអាក្រក់ហើយ រមែងត្រូវប្រហារដោយញញួរដែក" ។

៤ - អង្គារកាសុនរក: នរករងើកភ្លើង គឺនរករណ្តៅរងើកភ្លើង ក្នុងនរកនេះ ពួកសត្វនរកត្រូវនាយនិរយបាល ដេញវាយដោយញញួរដែកក្រហមក្តៅ ឲ្យចុះទៅក្នុងរណ្តៅរងើកភ្លើង ពួកសត្វនរកធ្លាក់ទៅក្នុងរណ្តៅរងើកភ្លើងត្រឹមចង្កេះ ចំណែកពួកនាយនិរយបាល បានយកកន្ត្រងដែកធំ ៗ ដួសជង់រងើកភ្លើងដែកក្រហម ចាក់តរបន្ថែមលើក្បាលទៀត សត្វនរកទាំងនោះ កាលមិនអាចអត់ទ្រាំកំដៅបាន ក៏នាំគ្នាយំអន្ទះអន្ទែងខ្លោចផ្សា ។

បាបកម្ម ដែលនាំឲ្យធ្លាក់នរកនេះ លោកពោលទុកត្រឹមតែម្យ៉ាង មានគាថានិពន្ធថា :

យេ កេចិ បូគាយ ធនស្ស ហេតុ
សក្ខឹ ករិត្វា ឥណំ ជាបយន្តិ

តេ ជាមយិត្វា ជនតំ ជិនិទ្ធ
តេ លុទ្ទកម្មា បសវេត្វ បាបំ
តេមេ ជនា អង្គារកាសុំ បុនត្តិ ។

ប្រែថា " ជនណា ដើរបោកប្រាស់សទ្ធាទេយ្យរបស់អ្នកស្រុកមកបរិ-ភោគ ដោយអាងថាយកទៅសាងថាវរៈវត្ថុ ឬបូជាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ កាលបុគ្គលនោះស្លាប់ហើយ រមែងធ្លាក់នរកនេះកើតឡើង " ។

៥ - លោហកុម្ភីនរកៈ នរកខ្ទះទង់ដែង (អធិប្បាយរួចហើយ) ។

៦ - អយោទកនរកៈ នរកទឹកដែកក្រហមក្នុងនរកនេះ ពួកនាយនិរយបាល យកខ្សែដែកដែលឆេះជាអណ្ដាតភ្លើង ចងកសត្វនរកទាំងឡាយ ទាញកន្ត្រាក់ឲ្យដួលចុះ ហើយរឹតមូលកឲ្យដាច់ទៅ ដូចមូលកហាបឬកមាន់ ហើយបោះចុះទៅក្នុងទឹកក្ដៅ មានគាថាពន្យល់ថា :

លុញ្ចន្តិ គីវំ អថ យេចយិត្វា
ឧណ្ហោទកស្មិំ បកិលេទយិត្វា ។

ប្រែថា " ពួកនាយនិរយបាល ចងកសត្វនរកហើយមូលឲ្យដាច់ ហើយបោះចុះទៅក្នុងទឹកក្ដៅ " ក្នុងអដ្ឋកថា ថា សត្វក្នុងនរកនេះមាន

ខ្ពនកំពស់ ៣០០ សិន កាលត្រូវនាយនិរយបាលមួលកដាច់ហើយ ក៏មានកដទៃទៀតកើតឡើងជំនួសសោយទុក្ខតទៅ ។

បាបកម្មដែលនាំឲ្យធ្លាក់នរកនេះ បានដល់អ្នកធ្វើបាបជាព្រានសត្វ មានគាថា សាធកៈ ថា ៖

យេ ជីវលោកស្មឹ សុបាបធម្មិនោ
បក្ខី គហេត្វាន វិហេឋយន្តិ ។
តេ ហេឋយិត្វា សកុណំ ជនិន្ទ
តេ លុទ្ទកម្មា បសវេត្វ បាបំ
តេមេ ជនា លុត្តវិសា សយន្តិ ។

ប្រែថា " មនុស្សមានចិត្តអាក្រក់ឯណា ក្នុងជីវលោកនេះ បៀតបៀនសត្វស្លាបទាំងឡាយ មនុស្សដែលមានចិត្តអាក្រក់ទាំងនោះ រមែងត្រូវមួលក ( ឲ្យដាច់ ) ។

៣ - បិសធរក នរកអង្កាម ក្នុងនរកនេះជាស្ទឹងមួយដែលមានទឹកថ្លាពេញប្រៀប កាលពួកសត្វនរក ត្រូវសេចក្តីក្តៅដោយអណ្តាតភ្លើងក្នុងខណៈដែលទៅលើផែនដែកក្រហម , លុះឃើញស្ទឹងនោះ ក៏ចូល

គិតថានឹងបានងូតទឹកសប្បាយ តែកាលលោកចុះទៅ ហើយទឹកនោះចូលទៅដល់កទ្រោះ ទឹកនោះក៏ក្លាយជាអង្កាមក្តៅ ឆេះពោះវៀនដាចជាកំណាត់ៗ ហើយហូរធ្លាក់ចុះទៅតាមផ្លូវក្រោម មានគាថាបញ្ជាក់ថា:

ពហុតោយា អនិខាតកូលា
នទី អយំ សន្ទតិ សុបតិត្ថា
ឃម្មាភិតត្តា មនុជា បិវន្តិ ។

ប្រែថា " ស្ទឹងនេះ ពេញទៅដោយទឹក មានច្រាំងមិនជ្រៅ មានកំពង់ល្អ ពួកសត្វនរកទាំងឡាយ ដែលត្រូវសេចក្តីក្តៅក្រហាយគ្របសង្កត់ហើយ រមែងផឹកទឹកក្នុងស្ទឹងនោះ ទឹកដែលផឹកនោះទៅហើយ រមែងក្លាយជាអង្កាម " ។

កម្មដែលនាំឲ្យធ្លាក់នរកនេះ បានដល់ការយកស្រូវស្អកឬអង្កាម ( ប្រកបបាវការ ) បន្លំធ្វើជាស្រូវល្អលក់ មានគាថាជាបង្ហាញថា:

យេ សុទ្ធធញ្ញំ បលាសេន មិស្សំ
អសុទ្ធកម្មា កយិនោ ទទន្តិ
ឃម្មាភិតត្តាន បិបាសិតានំ

មិត្តញ្ញូ តេសំ បុសំ ហោតិ ជាតិ ។

ប្រែថា "មនុស្សឯណាមានចិត្តមិនបរិសុទ្ធ បានលាយស្រាដែលល្អសុទ្ធដោយអង្កាម លក់ឲ្យអ្នកដទៃ មនុស្សនោះ គ្រាត្រូវសេចក្ដីក្ដៅគ្រប់សង្កត់ហើយមានសម្រែកស្រែកទឹក ទឹកដែលគេដាក់ចូលទៅក៏ក្លាយជាអង្កាម" ។

៨ - អយសូលនរក: នរកបម្រុងដែក លោកសំដែងទុកថា មានពួកនាយនិរយបាលចាំចាក់ស្ពឹងផ្ងឹងសត្វនរកដោយអាវុធផ្សេងៗ មានបម្រុងដែកជាដើម រាងកាយសត្វនរកទាំងនោះ ធ្លុះធ្លាយជាកំណាត់តូចកំណាត់ធំ មានគាថាសំដែងទុកថា :

ឧស្សូហិ សត្តិហិ ច តោមរេហិ
ឧភយានិ បស្សានិ តុទន្តិ កន្ទតំ ។

ប្រែថា "នាយនិរយបាលទាំងឡាយ រមែងចាក់ស្ពឹងជំនីទាំងពីររបស់ពួកសត្វនរកដែលស្រែកគ្រាំគ្រាទោដោយបម្រុងនិងលំពែង និងដែកស្រួច"

ច្បាប់កម្មដែលនាំឲ្យធ្លាក់នរកនេះ លោកពោលទុកត្រឹម ៣ គឺការល[illegible] យ៉ាងមានគាថាសំអាងថា :

យេ ជីវលោកស្មឹ អសាធុកម្មិនោ

អទិន្នមាទាយ ករោន្តិ ជីវិតំ

ធញ្ញំ ធនំ រជតំ ជាតរូបំ

អជេឡកញ្ចាបិ បសុំ មហិំសំ

តេ លុទ្ទកម្មា បសវេត្វ បាបំ

តេមេ ជនា សត្តហតា សយន្តិ ។

ប្រែថា "ជនពួកណា ដែលជាអ្នកចូលចិត្តប្រព្រឹត្តធ្វើអំពើមិនល្អ ក្នុងជីវលោកនេះ បានលួចយកស្រូវអង្ករ, ទ្រព្យមាសប្រាក់, ចៀម គោក្របីរបស់អ្នកដទៃមកចិញ្ចឹមជីវិត ពួកអ្នកដែលធ្វើអំពើមិនល្អទាំងនោះ លុះធ្វើសេចក្តីអាក្រក់ហើយរមែងត្រូវចាក់ដោយលំពែង ។

៩ – សញ្ជោតិនរកៈ នរកអាវុធដែកក្រហម លោកសំដែងទុកថា មានពួកនាយនិរយបាលចងកសត្វនរកដោយខ្សែដែកដ៏ធំ ដែលឆេះដាអណ្តាតភ្លើង ទាញអូសទៅតាមផែនដីដែកដ៏ឆេះសន្ធោសន្ធៅ គ្រាសត្វនរកដួលចុះហើយ ក៏កាប់ដំដោយអាវុធផ្សេងៗ មានគាថាបញ្ជាក់ថា :

តិរាយ ពន្ធា កិស្សិមេ បុនេកេ

អញ្ញេ វិកន្តា វិលកតា សយន្តិ ។

ប្រែថា "ពួកសត្វក្នុងនរកនេះ រមែងមាននាយនិរយបាល យក ខ្សែបន្ទុកសំឡេះសាច់ចេញ ជាកន្ទុកដូចសំឡេះសត្វព្រៃ" ។

ក្នុងអដ្ឋកថា ថា សត្វក្នុងនរកនេះ ត្រូវនាយនិរយបាលសំឡេះ សាច់បន្ទុកជាកន់ ៗ ។

កម្មដែលនាំឲ្យមានកំហុស បណ្តាលឲ្យធ្លាក់ចុះនរកនេះ លោកថា ទុកតែត្រឹម សំឡាប់សត្វលក់ មានគាថាជាបទដ្ឋានថា :

ឱរព្ភិកា សូករិកា ច មច្ឆិកា
បសុំ មហិសញ្ច អជេឡកញ្ច
ហន្ត្វាន សូណេសុ បសារយឹសុ
តេ លុទ្ទកម្មា បសវេត្វ បាបំ
តេមេ ជនា វិលកតា សយន្តិ ។

ប្រែថា "បុគ្គលណា សំឡាប់ពពែ ចៀម ជ្រូក ត្រី គោ ក្របី ហើយនាំទៅលក់ទីផ្សារ បុគ្គលនោះ ត្រូវនាយនិរយបាលសំឡេះសាច់ ចេញទុកជាកន់ៗ

១០_ គូថនរក: នរកដុំលាមក (អធិប្បាយរួចហើយ

១១_ លោហិតបុព្វនរក: នរកឈាមនិងខ្ទុះ ពួកសត្វក្នុងនរកនេះ បានដឹកស៊ីតែឈាមនិងខ្ទុះ មានគាថានិពន្ធថា

វហាទោ អយំ លោហិតបុព្វបូរោ
ទុគ្គន្ធរូបោ អសុចិ បូតិ ភាយតិ
យម្ហាភិតត្តា មនុជា បិវន្តិ ។

ប្រែថា "នរកនេះ ពេញទៅដោយឈាមនិងខ្ទុះជារបស់ស្អោកគ្រោកគួរខ្ពើម ពួកសត្វក្នុងនរកនេះ រមែងដឹកស៊ីឈាមនិងខ្ទុះជួសគាប់បាយទឹក ព្រោះអត់ទ្រាំសេចក្តីស្រេកឃ្លានមិនបាន" ។

បាបកម្មដែលនាំឲ្យធ្លាក់នរកនេះ បានដល់ការសម្លាប់មាតាបិតានិងព្រះអរហន្ត មានគាថាដាក់គាំងថា

យេ មាតរំ បិតរំ វា ជីវលោកេ
បារាជិកា អរហន្តេ ហនន្តិ
តេ លុទ្ទកម្មា បសវេត្វ បាបំ
តេមេ ជនា លោហិតបុព្វភក្ខា ។

ប្រែថា "ជនពួកណា ក្នុងជីវលោកនេះ ជាអ្នកសម្លាប់មាតាបិតា ឬសម្លាប់ព្រះអរហន្ត ជនពួកនោះ ចាត់ជាមនុស្សអាក្រក់ លុះធ្វើសេចក្តីអាក្រក់ហើយ រមែងមានឈាមនឹងខ្ទុះជាអាហារ" ។

ក្នុងអដ្ឋកថា ពន្យល់សេចក្តីថា មិនមែនត្រឹមតែសម្លាប់ព្រះអរហន្តប៉ុណ្ណោះទេ សម្លាប់ភិក្ខុសង្ឃសាវកដទៃ ៗ ក៏ត្រូវធ្លាក់ក្នុងនរកនេះដែរ ។

១២ **កូដិការនរក**: នរកមនុស្សកោង ក្នុងនរកនេះមានពួកនាយនិរយបាល យកសន្លុចដែកធំ ៗ ប៉ុនដើមត្នោត ការថ្ពក់អណ្តាតរបស់សត្វនរក សន្ទឹងទុកនឹងផែនដែកក្រហម ដូចគេបោះសន្ទឹងស្បែកភ្ជាប់ទុកលើផែនដី មានគាថានិពន្ធទុកមកថា :

ជិវ្ហញ្ច បស្ស ពលិសេន វិទ្ធំ
វិហតំ យថា សង្កុសកេន ចម្មំ
ផន្ទន្តិ មច្ឆាវ ថលម្ហិ ខិត្តា
មុញ្ចន្តិ ខេឡំ រុទមានា កិមេតេ ។

ប្រែថា "ចូរមើល ; សត្វនរក ដែលត្រូវការថ្ពក់អណ្តាតនិងសន្ទូចត្រដាងសន្ទឹងទុកដូចត្រដាងស្បែក រមែងសន្ទុះអន្ទុងដូចជាត្រី ដែលគេ

ចាប់ផ្ទោះទៅលើគោក មានតែយំយោគយូរទឹកភ្នែកស្រោកស្រាក់ ៗ

កម្មដែលនាំឲ្យធ្លាក់នរកនេះ បានដល់ការដំឡើងថ្លៃវត្ថុ ច្រើនជ្រួសហួសហេតុ ដោយឃើញដល់ការចំណេញ មានគាថាជាបទដ្ឋានថា:

យេ កេចិ សណ្ឋានគតមនុស្សា
អគ្ឃេន អគ្ឃំ កយំ ហាបយន្តិ
កូដេន កូដំ ធនលោភហេតុ
ឆន្នំ យថា វារិចរំ វធាយ
នហិ កូដការិស្ស ភវន្តិ តាណា
សកេហិ កម្មេហិ បុរក្ខិតស្ស
តេ លុទ្ទកម្មា បសវេត្វ បាបំ
តេមេ ជនា វង្កឃស្តា សយន្តិ ៗ

ប្រែថា "បុគ្គលណាបាន ទទួលរ៉ៃដម្លៃលក់របស់ហើយរ៉ៃថ្លៃគោងវៀចវេរ ព្រោះឃើញដល់ទ្រព្យ បំណែកសំដីនិយាយទន់ភ្លន់ផ្អែមល្ហែមពិរោះដើម្បីបិទបាំងលាក់លៀមគោងវៀចរបស់ខ្លួន ដូចមនុស្សដែលអែបខ្លួនពួនបាញ់សត្វ អ្នកដែលគោងវៀចដូចនេះ រមែងមិនមាន

អ៊ីការពារមិនឲ្យធ្លាក់នរកបានទេ  កាលស្លាប់ហើយរមែងត្រូវសន្ធុចធ្លាក់អណ្ដាតក្នុងនរកនេះ ។

១៣ – អយបព្វតនរក: នរកភ្នំដែក ក្នុងនរកនេះ ពួកសត្វនរកត្រូវចាប់បោះទៅក្នុងទឹកទង់ដែងខ្ទុះ  ត្រូវភ្នំសង្កត់សង្កិនខ្ទុះ  មានគាថាជាគ្រឿងបញ្ជាក់ថា

នារី ឥមា សម្បរិភិន្នគត្តា
បគ្គយ្ហ កន្ទន្តិ ភុជា ទុជច្ចា
សុមក្ខតា លោហិតបុព្វលិត្តា
គាវោ យថា អាឃាតនេ វិកន្តា
ឧទ្ធាតិ វត្តន្តិ សជោតិភូតា ។

ប្រែថា  ស្រីពួកនេះ  ត្រូវនាយនិរយបាលចាក់រាងកាយសព្វសុះនាំគ្នាលើកដៃស្រែកយំ  មានរាងកាយប្រលាលរន្ទាលទៅដោយឈាមនិងខ្ទុះ  ពួកនាយនិរយបាលដេញឲ្យចុះទៅក្នុងដែនដែកក្រហមត្រឹមចង្កេះនឹងកម្រើកងាករេទោមកមិនបាន  ដូចគោដែលគេឃុំឃាំងទុកក្នុងក្រោលសម្រាប់សម្លាប់ ស្រីពួកនេះមានរាងកាយដំណាត់ឆេះជាអណ្ដាតភ្លើង ” ។

ក្នុងអដ្ឋកថា ថា ស្រីសត្វនរកពួកនេះ មានរាងកាយធំប៉ុនភ្នំ ក្នុងខណៈដែលនាយនិរយបាលឃុំឃាំងទុកលើដែនដែកក្រហម លិចចុះទៅត្រឹមចង្កេះនោះ មានភ្នំដែកដែលឆេះជាអណ្តាតភ្លើង រមៀលមកអំពីទិសទាំង៤ សង្កត់សង្កិនកំទេចស្រីពួកនោះឲ្យល្អិតជាធូលីទៅ ។

កម្មដែលនាំឲ្យធ្លាក់នរកនេះ បានដល់ការប្រព្រឹត្តិក្រៅចិត្តស្វាមី មានពាក្យបាលីបញ្ជាក់ថា :

កោលិត្ថិយា យោ ឥធ ជីវលោកេ
អសុទ្ធកម្មា អយុត្តំ អចារុំ
តា ធុត្តរូបា បតឹ វិប្បហាយ
អញ្ញំ អចារុំ រតិខិឌ្ឌហេតុ
តា ជីវលោកស្មឹ រមាបយិត្វា
ខន្ធាតិ វត្តន្តិ សជោតិភូតា ។

ប្រែថា «ស្រីពួកណា ក្នុងជីវលោកនេះ ជាអ្នកទុច្ចរិតប្រព្រឹត្តដ៏មិនសមគួរ គឺប្រព្រឹត្តផិតក្រៅចិត្តស្វាមីគប់រកបុរសដទៃ ព្រោះឃើញដល់សេចក្តីត្រេកត្រអាលរីករាយ លុះស្រីពួកនោះស្លាប់ហើយរមែងធ្លាក់...

ក្នុងនរកនេះ មានរាងកាយធំប៉ុនភ្នំ ត្រូវភ្លើងឆេះសន្ធោសន្ធៅនៅជានិច្ច ។

១៤ - ជលិតអង្គារនរក: នរករណ្តៅរងើកភ្លើង ក្នុងនរកនេះ មានរណ្តៅធំៗ ពេញទៅដោយរងើកភ្លើង ពួកនាយនិរយបាលដេញចាក់ពួកសត្វនរកទៅលើផែនដែកក្រហមទាំងហ្វូង ៗ ដូចហ្វូងគោក្របី លុះដេញទាន់ហើយ ក៏ចាប់បោះចុះទៅក្នុងរណ្តៅរងើកភ្លើងដ៏ក្តៅនេះជានិច្ច មានគាថាភាសិតថា:

បាទេ គហេត្វា កិស្សមេ បុនេកេ
អវំសិរា នរកេ បាតយន្តិ ។

ប្រែថា " ពួកសត្វក្នុងនរកនេះ ត្រូវនាយនិរយបាលចាប់យកជើងឡើងលើ យកក្បាលសំយុងចុះក្រោម បោះចុះទៅក្នុងនរក " ។

បាបកម្មដែលនាំឲ្យធ្លាក់នរកនេះ បានដល់ការប្រព្រឹត្តអនាចារនឹងភរិយាអ្នកដទៃ មានគាថាសំអាងថា:

យេ ជីវលោកស្មិំ អសាធុកម្មិនោ
បរស្ស ទារានិ អតិក្កមន្តិ
តេ តាទិសា ឧត្តមភណ្ឌថេនា

តេមេ ជនា (អវិសិវា) នរកេ បាតយន្តិ
តេ វស្សបូគានិ ពហូនិ តត្ថ
និរយេសុ ទុក្ខំ វេទនំ វេទយន្តិ
ន ហិ បាបការស្ស ភវន្តិ តាណា
សកេហិ កម្មេហិ បុរក្ខិតស្ស
តេ លុទ្ទកម្មា បសវេត្វ បាបំ
តេមេ ជនា (អវំសិវា) នរកេ បាតយន្តិ ។

ប្រែថា "បុរសពួកណា ក្នុងជីវលោកនេះ ជាអ្នកធ្វើកម្មមិនល្អ គឺកន្លងប្រវេណីនឹងភរិយាអ្នកដទៃ បុរសពួកនោះ ត្រូវនាយនិរយបាលដាក់ក្បាលសំយុងចុះ ធ្លោះចុះទៅក្នុងនរកអស់កាលដ៏យូរយារ បុរសដែលកសាងសន្សំធ្វើសេចក្ដីអាក្រក់ក្នុងទាំងនោះ រមែងមិនមានអ្នកការពារ លុះគ្រាស្លាប់ហើយ រមែងត្រូវនាយនិរយបាលចាប់ក្បាលសំយុងចុះក្រោម :ចុះទៅក្នុងនរក ។

១៥ - មិច្ឆាទិដ្ឋិកនរកៈ នរកអ្នកមិច្ឆាទិដ្ឋិ គឺពួកអ្នកដែលយល់ឃើញខុស រមែងធ្លាក់នរកនេះ មានគាថាជាគ្រឿងសំអាងថា:

ឧច្ចាវចាមេ វិវិធា ឧបក្កមា
និរយេសុ ទិស្សន្តិ សុឃោររូបា ។

ប្រែថា "សត្វនរកពួកនេះ សុទ្ធតែជាអ្នកប្រកបដោយកម្ម មានរូបរាងគួរខ្លាចនៅក្នុងនរកនេះ" ។

ក្នុងអដ្ឋកថាថា: ពួកសត្វក្នុងនរកនេះ សុទ្ធតែជាអ្នកមានសេចក្ដីយល់ឃើញខុស គឺយល់ឃើញថា "ឲ្យទានមិនបានផល, ការបូជាធំមិនមានផល, ការបូជាតូចមិនមានផល, ការធ្វើល្អអាក្រក់មិនមានផល, មាតាមិនមាន, បិតាមិនមាន, សត្វដែលជាឧបបាតិកមិនមាន, លោកនេះមិនមាន, លោកខាងមុខមិនមាន" មានគាថាបញ្ជាក់ថា:

យេ ជីវលោកស្មឹ សុបាបទិដ្ឋិនោ
វិស្សាសកម្មានិ ករោន្តិ មោហា
បរញ្ច ទិដ្ឋីសុ សមាទបេន្តិ
តេ បាបទិដ្ឋី បសវេត្វ បាបំ
តេមេ ជនា អធិមត្តា ទុក្ខា តិប្បា
ខរា កដុកា វេទនា វេទយន្តិ ។

ប្រែថា "បុគ្គលពួកណា ក្នុងលោកនេះ ជាអ្នកមានសេចក្តីយល់ឃើញខុស ព្រោះមោហៈធ្វើបាបកម្មផ្សេងៗ ដោយខ្លួនឯងខ្លះ ដឹកនាំឲ្យបុគ្គលដទៃយល់ខុសតាមខ្លួនខ្លះ បុគ្គលពួកនោះលុះស្លាប់ហើយ រមែងបានទទួលសេចក្តីទុក្ខយ៉ាងធំ មានទុក្ខវេទនាដ៏ក្តៅក្រហាយផ្សាយក៏ង ពន់ពេកអនេកអនន្តណាស់ ៗ

## និគមភាសិត

ទី ១ វេតរណីនទី ទី ២ សុនខនរក

ទី ៣ អយបបរីណា ទី៤ អង្គារការសុនរក ៗ

៥ នរកលោហកុម្ភី ទី ៦ អបេរាទកៈ

ទី ៧ នរកថុសៈ ៨ អយស្ទូលៈណា ៗ

៩ សញ្ជោតិនរក ទី ១០ គូថនរក

១១ លោហិតបុព្វកា ១២ ល្ហាភៈកូដការី ៗ

១៣ អយបពុត ១៤ ជលិតអង្គារនៃ

១៥ គីមិច្ឆាទិដ្ឋី រួមត្រូវជា ១៥ រណ្តៅ ៗ

នរកទាំងនេះតែសុទ្ធ សាន្ត សត្វសឹងនានាបានស្តោកសៅ សែន

ទុក្ខបុកម្រេញក្តួលក្តៅ  សមតាមកម្មខ្មៅដែលខ្លួនសាង  គួរកោតគួរ

ខ្លាចគួរកុំធ្វើ  អំពើអាក្រក់គ្រប់បែបយ៉ាង  អកុសលកម្មគ្មានផ្លូវអាង  មុខ

ជាដួលធ្លាក់ទៅអបាយ  បើមិនតិរច្ឆានក៏តង់ប្រេត  បើមិនប្រេតតង់អសុរ

កាយ  ឬធ្លាក់នរកផងទាំងឡាយ  គ្រហល់គ្រហាយឥតសាន្តសុខ

ណាត្រឹបណ្ដិតប្រិតប្រឹងប្រែង  ប្រែតែងរៀបរៀងរឿងនរក  ចាកនេ-

មិរាជជាតក  សាធកសង្ខេបប៉ុណ្ណោះហោង ។

ចប់រឿងនរកក្នុងនេមិរាជជាតក

# និរយកថា

(តាកសង្កិច្ចជាតក).

## នមត្ថុ រតនត្តយស្ស

ក្នុងសង្កិច្ចជាតក ពោលថា ព្រះពោធិសត្វទ្រង់នាមថា សង្កិច្ច តាបស បានលុះអភិញ្ញាសមាបត្តិ បានសំដែងនរកដោយអំណាចឥទ្ធិ-ឫទ្ធិ ថ្វាយដល់ព្រះបាទពារាណសី ដោយបញ្ជាក់ប្រភេទនរកនិងបាន-កម្មដែលឲ្យធ្លាក់នរកទុកដូចតទៅនេះ ។

## នរកធំ ៨

នរកធំ ៨ គឺ: សញ្ជីវៈ, កាឡសុត្តៈ, សង្ឃាតៈ, ជាលរោរុវៈ, ធុមរោរុវៈ, មហាអវេចី, តាបនៈ, បតាបនៈ, ។

នរកធំទាំង ៨ នេះ មានឧស្សុទនរករណ្តៅតូច ១៦ ។ ជាបរិវារ ជាទីដែលបុគ្គលអ្នកធ្វើបាបឲ្យក្តៅក្រហាយក្រហល់ខ្លោចផ្សា គួររន្ធត់ស្លុតក្តុំក្តិន គួរខ្លាច មានអណ្តាតភ្លើង មានភ័យធំគួរញញើត គួរស្ញប់ស្ញែងក្រៃលែង មានភ័យជុំវិញ មានសេចក្តីលំបាកច្រើន មានរណ្តៅ ៤ ទ្វារ ៤ បែងជាទ្វារមានផ្លូវចូលដោយទ្វារ មានកំពែងដែកជុំវិញ មានគ្របដែកបិទជិតត្រង់កណ្តាល អណ្តាតភ្លើងសន្ធោសន្ធៅ មានសេចក្តីក្តៅ

ឡោចអណ្តាតភ្លើងផ្សាយរហូត ១ រយ យោជន៍សព្វកាល ។

## ប្រែនិងអធិប្បាយនរកធំទាំង ៨

ពាក្យថា សញ្ជីវៈ ប្រែថា "រស់ឯង" អធិប្បាយថា: សត្វក្នុងនរកនេះ ត្រូវពួកនាយនិរយបាលសាប់កាប់ឲ្យដាច់ជាកំណាត់តូចកំណាត់ធំ ដោយអាវុធផ្សេងៗដែលឆេះជាអណ្តាតភ្លើង កាលស្លាប់ហើយមានខ្យល់ត្រជាក់ៗ ជាត់មកត្រូវ ក៏ត្រឡប់រស់ឡើងវិញរឿយៗ ។ សត្វនរកសញ្ជីវៈនេះ ត្រូវនាយនិរយបាលកាប់សាប់សម្លាប់សំឡេះខ្លះ ពួកសត្វក្នុងនរកនេះ សម្លាប់កាប់ចាក់គ្នាដោយដៃ ដែលបាបកម្មឲ្យក្លាយជា ដាវ លំពែង កាំបិត ប៉ូវថៅ ខ្លះត្រូវស្លាប់កើតទុក្ខទាល់វេទនានៅក្នុងនរកនេះ រហូតដល់អស់បាបកម្ម ឬ អស់អាយុដែលកំណត់ ។

ពាក្យថា កាឡសុត្តៈ ប្រែថា "ខ្សែបន្ទាត់ដែក" អធិប្បាយថា ក្នុងនរកនេះពួកនាយនិរយបាលដេញប្រកិតជិតជាប់តាមសត្វនរកទាំងឡាយ ទៅៗ មកៗ នៅលើផែនដែកក្រហមមិនបេះឈប់ កាលដេញទាន់ហើយក៏ប្រហារឲ្យដួលចុះ ហើយចងខ្សែដែកឲ្យដេកសន្ធឹងលើដែកក្រហម ហើយយកខ្សែបន្ទាត់ដែកផាត់ចុះតាមរាងកាយ ការសត្វនរកនោះក៏បែកជាក្រហែងៗទៅ បើផាត់វាងមុខក៏បែកមុខក្លាយ

ដល់ខាងក្រោយ បើផ្ទាត់ខាងក្រោយក៏បែកធ្លាយដល់ខាងមុខ ផ្ទាត់ខាងស្តាំធ្លាយដល់ខាងឆ្វេង ផ្ទាត់ខាងឆ្វេងធ្លាយដល់ខាងស្តាំ ;

កាលពួកសត្វនរកនេះ ស្តាប់ហើយក៏ត្រឡប់រស់ឡើងទៀត កាលរស់ឡើងដឹងខ្លួនមានសេចក្តីភ័យខ្លាច នឹងនរទ្រាំនៅមិនបាន ក៏រត់ទៅតាមផែនដែកក្រហម ត្រូវភ្លើងឆេះគ្រប់ដំបន់ កាលអស់កំឡាំងហើយក៏ដួលចុះ ត្រូវភ្លើងឆេះនឹងត្រូវនាយនិរយបាលធ្វើទណ្ឌកម្ម រហូតដល់អស់បាបកម្មនិងអាយុ ។

ពាក្យថា សង្ឃាតៈ ប្រែថា សង្កត់ខ្ទុំកំទេចខ្ទេចខ្ទី អធិប្បាយថា ក្នុងនរកនេះ មានភ្នំដែកធំៗ ដែលឆេះឆាវណ្តាតភ្លើង សម្រាប់រមៀលមកសង្កត់កំទេចឲ្យបែកល្អិត គឺនាយនិរយបាលចាប់បោះសត្វនរកទៅក្នុងផែនដែកដែលឆេះសន្ធោសន្ធៅ ដែលមានកម្រាស់បាន៩យោជន៍ ត្រឹមចង្កេះ មិនឲ្យកម្រើកខ្លួនបាន ហើយមានភ្នំដែកធំដែលឆេះឆាវណ្តាតភ្លើង រមៀលមកអំពីទិសខាងកើត សង្កត់សត្វនរកទាំងនោះឲ្យល្អិតដូចក្រាបល្អ ហើយរមៀលទៅតាំងនៅទិសខាងលិច ចំណែកភ្នំដែកទិសខាងលិចបានរមៀលទៅសង្កត់សត្វនរកទាំងនោះ ហើយទៅតាំងនៅខាងកើត ដូនកាលភ្នំទាំងពីរបានរមៀលទៅជួបគ្នាសង្កត់សត្វនរកក្នុ

ឲ្យបានទទួលទុក្ខវេទនានៅទាំងសែនឆ្នាំ ។

ពាក្យថា ជាលរោរុវៈ ប្រែថា យំដោយអណ្ដាតភ្លើង អធិប្បាយថា ក្នុងនរកនេះមានអណ្ដាតភ្លើង ស្រុបចូលទៅតាមទ្វារទាំងអស់នៃពួកសត្វនរក ហើយដុតកំដៅរាងកាយសត្វនរក ពួកសត្វនាំគ្នាយំរងំរង្គួយ ។

ពាក្យថា ធុមរោរុវៈ ប្រែថាយំដោយផ្សែងភ្លើង អធិប្បាយថា ក្នុងនរកនេះ មានផ្សែងភ្លើងហុយទ្រលោមជុំវិញសត្វនរកជានិច្ច ស្រុបចូលទៅតាមទ្វារទាំង ៩ ផ្សែងនោះ ជាផ្សែងដែលផ្សាយហ៊ានពន់ពេក ពួកសត្វនរកនេះ នាំគ្នាយំទួញសោយទុក្ខយ៉ាំងរហ៊ស ។

ពាក្យថា មហាអវេចិ ប្រែថា មិនចន្លោះ មិនទំនេរ អធិប្បាយថា ក្នុងនរកនេះ មានអណ្ដាតភ្លើងផ្សាយចេញមកអំពីទិសទាំង ៨ ផ្សាយទៅបាន ១០០ យោជន៍ជានិច្ច មិនមានវេលាទំនេរអណ្ដាតភ្លើងឡើយ ចំណែកខាងក្នុងដ៏ធំទូលាយដល់រយយោជន៍ ក៏មិនទំនេរសត្វនរក សត្វនរកនៅពេញទាំងអស់ ប្រជ្រៀតប្រជៀតគ្នានៅកកកុញកកកុះ ស្អកស្កះ ដូចដង្កូវនៅក្នុងបង្គន់ វេលាទំនេះចាកទុក្ខរបស់សត្វនរកទាំងនោះក៏មិនមាន ក្នុងមហាអវេចិនរកនោះរាស់ត្រង់កណ្ដាលឋាន

៣១៨ យោជន៍ កស់ដោយជុំវិញបាន៩៥៤ យោជន៍ រួមទាំងស្រុង នរកជង់បាន ១ម៉ឺនយោជន៍

ពាក្យថា តាបន ប្រែថា ធ្វើឲ្យក្តៅ អធិប្បាយថា ក្នុងនរកពួកនេះនាយនិរយបាលចៀបសត្វនរកនុក ដោយដើរប៉ែកដែកធំប៉ុនដើមត្នោត ដែលឆេះជាអណ្តាតភ្លើង មិនឲ្យកម្រើកកម្រើកបាន ចំណែកផែនភាគខាងក្រោមក៏ឆេះជាអណ្តាតភ្លើង ឆេះពួកសត្វនរកទាំងនោះ ។

ពាក្យថា បតាបនៈ ប្រែថា ធ្វើឲ្យក្តៅទួទៅ អធិប្បាយថា ក្នុងនរកនេះ ពួកនាយនិរយបាលដេញវាយសត្វនរកដោយអាវុធដែលឆេះជាអណ្តាតភ្លើង ដេញឲ្យឡើងភ្នំភ្លើង កាលពួកសត្វនរកឡើងទៅដល់លើភ្នំហើយ ក៏មានខ្យល់ធំផាត់ឲ្យធ្លាក់ចុះមក ត្រូវចុងដែកស្រួចខាងក្រោមទៀត ។

## បាបកម្មដែលនាំឲ្យធ្លាក់នរក

...កម្មដែលឲ្យធ្លាក់នរកធំទាំងនេះក្តី ឬឲ្យធ្លាក់នរកតូចដែលជាបរិវារ ...ក្តី ...លោកសំដែងហើយខ្លះ ចំណែកនរកតូចលោកក៏មិនបានបែកនុក ត្រាន់តែជាក្តី... សំដែងដល់បាបកម្មដែលឲ្យធ្លាក់

នរក និងបាបកម្មដែលឲ្យធ្លាក់នរកនោះ ក៏ពោលទុកដោយរឿងដូចតទៅនេះ ។

១ - អ្នកប្រទូស្តរ៉ាយព្រះឫសីដែលមានសីលធម៌ល្អ ត្រូវធ្លាក់នរកធំរហូតកាលដ៏យូររាប់ឆ្នាំមិនបាន ។

២ - ព្រះរាជាដែលមិនតាំងនៅក្នុងធម៌ ធ្វើឲ្យរាស្ត្រប្រជាក្តៅក្រហាយដោយអយុត្តិធម៌ ធ្លាក់ក្នុងតាបននរក បានសោយទុក្ខវេទនាដោយត្រូវភ្លើងឆេះចេញចាករាងកាយ របស់សត្វនរកដែលកើតមុនឆេះនៅជានិច្ច ។

៣ - អ្នកសម្លាប់បិតា ធ្លាក់កាឡសុត្តនរកខ្លះ ធ្លាក់លោហកុម្ភីនរកខ្លះ ពួកនាយនិរយបាលក្នុងលោហកុម្ភីនរកនោះ ចាក់ទុកដោយលំពែងតាមរាងកាយខ្លះ ចាក់ឲ្យភ្នែកខ្វាក់ខ្លះ ឲ្យស៊ីមូត្រគូថខ្លះ ឲ្យស៊ីដុំដែកក្រហមខ្លះ ត្រូវពួកសុនខនិងក្អែកហែកចិកស៊ីសាច់ឈាមខ្លះ បោះចុះទៅក្នុងទឹកដ្យាមុកខ្លះ ។

៤ - អ្នកសម្លាប់មាតាក៏ធ្លាក់ក្នុងនរកទាំងពីរនេះ ត្រូវនាយនិរយបាលគ្មូរដោយដាលដែកក្រហមខ្លះ ផឹកស៊ីលោហិតរបស់ខ្លួនខ្លះ ផឹកទឹកទន់ដែខ្លះ ត្រាំនៅក្នុងទឹកមូត្រគូថខ្លះ ត្រូវដង្កូវធំចាក់ជាដែកបោះរាងកាយខ្លះ

ធ្លាក់ចុះក្នុងទឹកលាមកនិងខ្ទុះដ៏ជ្រៅកប់រយយោជន៍ខ្ទុះ ។

៥ - ស្រីដែលធ្វើឲ្យធ្លាក់ គឺសម្លាប់កូនក្នុងពោះ ធ្លាក់វេតរណីនរក ដែលពេញទៅដោយផ្តៅមានបន្លាដ៏មុត ។

៦ - បុរសប្រព្រឹត្តកន្លងនឹងភរិយាអ្នកដទៃក្តី ស្រីដែលប្រព្រឹត្តផិតក្រៅចិត្តស្វាមីក្តី ពីរប្រភេទនេះ ធ្លាក់ក្នុងសិម្ពលីនរក ដែលពេញទៅដោយដើមរកា មានពាក់កាយកំពស់បាន ១ យោជន៍ ត្រូវពួកនាយនិរយបាលដេញចាក់ឲ្យឡើងដើមរកា ក្នុងវេលាឡើងបន្លារកាចាក់ផា អណ្តាតភ្លើងក្នុងចុងចុះមក ក្នុងវេលាចុះ បន្លារកាបះច្រាសឡើងលើ គ្រារួចចាកនរកនេះហើយ ធ្លាក់ទៅក្នុងលោហកុម្ភីនរក ដែលពេញទៅដោយទឹកទង់ដែងទៀត ។

៧ - ស្រីដែលគេលោះមកធ្វើជាភរិយា ហើយមើលងាយមាក់ថោកស្វាមី ឬមើលងាយឪពុកម្តាយរបស់ប្តី ធ្លាក់ក្នុងតាបននរក ត្រូវនាយនិរយបាលយកសន្ទូចថ្កក់ទាញអណ្តាតចេញមក អណ្តាតនោះវែង ពេញទៅដោយដង្កូវ ។

៨ - អ្នកសម្លាប់ពពែ, សម្លាប់ជ្រូក, សម្លាប់គោ សម្លាប់ដក់ឡើ ធ្វើការរកស៊ី ជាព្រានស៊ីសៀតញុះញង់អ្នកដទៃឲ្យបែកគ្នា , ដល់មាន់

ផល់គោ, ដល់ក្របី, ផល់ត្រី ធ្លាក់ការនទីនរក ដែលពេញទៅដោយទឹកដស្សា ត្រូវនាយនិរយបាលចាក់ដោយដែកស្រួច រាយសំពងដោយញញួរដែកគាប់សាប់ដោយដាវកាល់ព្រឹកល្ងាច ចំណែកអ្នកបង្កាច់បង្ខូចគេ ត្រូវនាយនិរយបាលឆ្អើទោសផង ស៊ីអាចម៍របស់សត្វនរកដទៃផង ត្រូវស៊ុន១និងត្បាតចឹកចោះផង ។

## បាលីក្នុងសង្កិច្ចជាតក

១ - សញ្ជីវោ កាឡសុត្តោ ច សង្ឃាតោ ទ្វេ ច រោរុវា
អថបរោ មហាវីចិ តាបនោ ច បតាបនោ
ឥច្ចេត អដ្ឋ និរយា អក្ខាតា ទុរតិក្កមា
អាកិណ្ណា លុទ្ទកម្មេហិ បច្ចេកា សោឡសុស្សទា
កទរិយ តាបនា ឃោរា អច្ចិមន្តោ មហាព្ភយា
លោមហំសនរូបា ច ភេស្មា បដិភយា ទុក្ខា
ចតុក្កណ្ណា ចតុទ្វារា វិភត្តា ភាគសោ មិតា
អយោបាការបរិយន្តា អយសា បដិក្កុជ្ជិតា ។
តេសំ អយោមយា ភូមិ ជលិតា តេជសា យុត្តា

សមន្តា យោជនសតំ ផុដ្ឋា តិដ្ឋន្តិ សព្វទា
ឯតេ បតន្តិ និរយេ ឧទ្ធំ បាទា អវំសិរា

## ពាក្យប្រែ

១ – នរកធំ ៨ គឺ សញ្ជីវៈ កាឡសុត្ត សង្ឃាត រោរុវ ម· អវិចិ តាបនៈ បតាបនៈ ។

នរកធំទាំង ៨ នេះ បណ្ឌិតទាំងឡាយបានពោលទុកថា ជាទីដែលកន្លងបានដោយក្រ ពេញទៅដោយអ្នកធ្វើកម្មអាក្រក់មានឧស្សទនរករណ្ដៅតូច ១៦ ។

នរកធំទាំង ៨ នេះ ជាទីធ្វើបុគ្គលអ្នកធ្វើបាបឲ្យក្ដៅក្រហាយ ជាទីគួរខ្លាច មានតែអណ្ដាតភ្លើងគួរខ្លាចច្រើន គួរស្លុត គួររន្ធត់ មានភ័យនៅជុំវិញ មានតែសេចក្ដីទុក្ខ ។ –

នរកធំទាំងនោះ នរកមួយ ៗ មាន ៤ ជ្រុង មានទ្វារ ៤ បែងជា ៤ ចំណែក ឡោមព័ទ្ធដោយកំពែងដែក មានគ្របដែលបិទជិត ។

ផ្ទៃរបស់នរកធំទាំងនោះ ជាដែកនេះជាអណ្ដាតភ្លើងដ៏ក្ដៅក្លាផ្សាយទៅបានទាំងរយយោជន៍គ្រប់កាលជានិច្ច ។

*អ្នកដែលធ្វើអំពើអាក្រក់ រមែងមានក្បាលសំយុងចុះក្រោម មាជើងឡើងលើ ធ្លាក់ចុះក្នុងនរកដំពាំងនោះ ។*

២- ឥសីនំ អតិវត្តារោ សញ្ញតានំ តបស្សិនំ
តេ ភូនហនា បច្ចន្តិ មច្ឆា ពិលកតា យថា
សំវច្ឆរេ អសំខេយ្យេ នរា កិព្ពិសការិនោ
ឌយ្ហមានេន គត្តេន និច្ចំ សន្តរពាហិរំ
និរយា នាធិគច្ឆន្តិ ទ្វារំ និក្ខមនេសិនោ
បុរត្ថិមេនបិ ធាវន្តិ តតោ ធាវន្តិ បច្ឆតោ
ឧត្តរេនបិ ធាវន្តិ តតោ ធាវន្តិ ទក្ខិណា
យំ យំ ទ្វារំ គច្ឆន្តិ តំ តំ ទេវ បិធិយរេ
ពហូនិ វស្សសហស្សានិ ជនា និរយគាមិនោ
ពាហា បគ្គយ្ហ កន្ទន្តិ បត្វា ទុក្ខំ អនប្បកំ
អាសីវិសំវ កុប្បិតំ តេជសី ទុរតិក្កមំ
ន សាធុរូបេ អាសីទេ សញ្ញតានំ តបស្សិនំ ។

# ពាក្យប្រែ

មនុស្សណាប្រព្រឹត្តកន្លងមើលងាយឫសីដែលមានសេចក្ដីសង្រួមល្អ មានតបៈធម៌ល្អ មនុស្សនោះរាតត្បាតអស់សេចក្ដីចំរើន ចាត់ថាជាអ្នកធ្វើសេចក្ដីអាក្រក់យ៉ាងក្លៀវក្លា ត្រូវឆេះនៅក្នុងនរកធំទាំងនោះ បានអន្ទះអន្ទែងដូចជាត្រី ដែលបុគ្គលស្រង់ចាកទឹក និងសោយទុក្ខជាច្រើនឆ្នាំរាប់មិនបាន ៕

អ្នកដែលត្រូវភ្លើងនរកឆេះជានិច្ច ទាំងខាងក្នុងទាំងខាងក្រៅរមែងរកផ្លូវចេញ តែចេញចាកនរកមិនបាន (ដោយមិនទាន់អស់កម្ម) ។ សត្វទាំងនោះរមែងរត់សំដៅទៅទ្វារខាងកើត ហើយរត់ត្រឡប់មកទ្វារខាងលិច រត់ទៅផ្លូវទ្វារខាងជើង ហើយរត់ត្រឡប់មកផ្លូវទ្វារខាងត្បូង ទៅដល់ទ្វារណាៗ ទ្វារនោះៗក៏បិទ ។

ពួកនោះត្រូវធ្លាក់នៅក្នុងនរកច្រើនពាន់ឆ្នាំ បានទទួលទុក្ខជាច្រើន អំគាលើកដៃឡើងយំ ។

ព្រោះដូច្នោះ នរណាៗ ក៏មិនគួរប្រកាន់លោកដែលល្អ គឺពួកព្រះឫសីដែលមានសេចក្ដីសង្រួមល្អ មានធម៌ល្អ ដូចគ្នានឹងបុគ្គលមិនគួរប្រកាន់អសិរពិស ដែលមានចិត្តឆេវឆាវ មានឫទ្ធិតេជៈខ្លាំងក្លាដូច្នោះ ។

៣- យោ ច រាជា អធម្មដ្ឋោ រដ្ឋំ វិទ្ធំសនោ ចុតោ
តាបយិត្វា ជនបទំ តាបនេ បេច្ច បច្ចតិ
យោ ច វស្សសហស្សានំ សតំ ទិព្យានិ បច្ចតិ ។
អច្ចិសិំឃបរេតោសោ ទុក្ខំ វេទេតិ វេទនំ
តស្ស អគ្គិសិខា កាយា និច្ឆរន្តិ បភស្សរា
តេជោ ភក្ខស្ស គត្តានិ លោមគ្គេហិ នខេហិ ច ។
ឌយ្ហមានេន គត្តេន និច្ចំ សន្តរពាហិរំ
ទុក្ខាភិតុន្នោ នទតិ នាគោ តុន្នទិតោ យថា

## ពាក្យប្រែ

ព្រះរាជាអង្គនោះ មិនតាំងនៅក្នុងធម៌ ធ្វើឲ្យពលរដ្ឋក្តៅក្រហាយដោយខុសច្បាប់ រមែងត្រូវភ្លើងឆេះក្នុងតាបននរក ។

ព្រះរាជាអង្គណា ច្រើនភ្លើងឆេះក្នុងតាបននរកច្រើនសែនឆ្នាំដែលរាប់ដោយឆ្នាំទិព្វ ព្រះរាជាអង្គនោះ មានតែត្រូវអណ្តាតភ្លើងឆេះនៅជុំវិញខ្លួន សោយតែទុក្ខវេទនា ព្រះរាជាអង្គនោះត្រូវអណ្តាតភ្លើងដែលឆេះចេញចាកកាយរបស់សត្វនរកដែលកើតមុនដុតកំដៅ ឆេះទាំងក្រចក

និងស្បែកកាប់ជាបានស៊ីកេក្អើន ។

ព្រះពជាអង្គនោះ ដែលត្រូវកេក្អើនគេ៖ តាំងខាងក្នុងនិងខាងក្រៅ នៅជានិច្ច មានតែទុក្ខទោសទណ្ឌចាក់ដោត ដូចដំរីដែលត្រូវកាប់ដោយកន្សែ ។

៤- យោ លោភា បិតរំ ហន្តិ ទោសា វា បុរិសាធមោ
ស កាយស្សហេតុ និរយេ បិរិំ រត្តាយ បស្សតិ ។
ស តាទិសោ បច្ចុ លោហកុម្ភិយំ
បក្កុច្ច សត្តិបិ ហនន្តិ និត្តំបិ
អន្ធំ ករិត្វា មុត្តករីសភក្ខំ
ខារេ និមុជ្ជន្តិ តថាវិធំ នរំ ។
តត្តំ បក្កុឋិតមយោគុឡញ្ច
ទីឃេ ច ជាលេ បិរត្តាបិតេ
វិក្កម្ភមាទាយ វិភជ្ជ រជ្ជុហិ
វិវតេ មុខេ សំសវយន្តិ រក្ខសា ។
សាមា ច សោណា សវលា ច គិជ្ឈា

កាលោលសំឃា ច ទិជា អយោមុខា
សំគម្ម ខាទន្តិ វិប្ផន្ទមានំ
ជិវ្ហំ វិភជ្ជ វិឃាសំ សលោហិតំ ៗ
តំ ទ្ឍ្យកោលំ បរិភិន្នគត្តំ
និប្បោថយន្តា អនុវិច្ចរន្តិ រក្ខសា
រតី ហិ តេសំ ទុខិនោ បនីតរេ
ឯតា ទិសស្មឹ និរយេ វសន្តិ
យេ កេចិ លោកេ ឥធ បេតឃាតិនោ ។

## ពាក្យប្រែ

អ្នកណាសម្លាប់បិតារបស់ខ្លួន ព្រោះសេចក្តីលោភឬសេចក្តីក្រោធ អ្នកនោះត្រូវធ្លាក់ឆេះនៅក្នុងកាឡសុត្តនរក រហូតកាលដ៏យូរយារ អ្នកសម្លាប់បិតានោះ រមែងឆេះខ្លោចនៅក្នុងលោហកុម្ភិនរក ត្រូវនាយនិរយ-បាលចាក់ដោយលំពែងតាមរាងកាយខ្លះ ចាក់ភ្នែកឲ្យទាល់តែខ្វាក់ខ្លះ បោះចុះទៅក្នុងទឹកជ្រាទឹកមូត្រខ្លះ ។

ពួកនាយនិរយបាល យកនង្គ័លដែកដ៏វែងដែលឆេះជាអណ្តាតភ្លើង

ឃ្លាសមាត់សត្វនរកទាំងនោះ ហើយយកខ្សែចងទុក ប្រកដុំដែកក្រហមដ៏ក្តៅចូលទៅក្នុងមាត់ខ្វះ ៗ ពួកដែកក្រហមដែកពពាល ក្អែកក្អាត តាដក់មានមាត់ចំពុះជាដែក ទាំចឹកស៊ីសត្វនរកដូចជាស៊ីរបស់ឆ្ងាញ់ពិសារ ដូច្នោះ ៗ ពួកនាយនិរយបាលដេញវាយសត្វនរកនោះ ឲ្យមានរាងកាយបែកជាចំរៀក ៗ ដូចគ្នានឹងកូនក្របៅ ដែលត្រូវភ្លើងឆេះ ការវាយសត្វនរកនោះ ជាសេចក្តីស្រួលសប្បាយរបស់នាយនិរយបាល ជាសេចក្តីទុក្ខរបស់ពួកសត្វនរក ពួកណាសំឡាប់បិតារបស់ខ្លួន ពួកនោះរមែងធ្លាក់នរក ដូចពោលមកហើយនេះ ៗ

៥- បុត្តោ ច មាតរំ ហន្ត្វា ឥតោ គន្ត្វា យមក្ខយំ
ភុសមាបជ្ជតេ ទុក្ខំ អត្តកម្មផលូបគោ ៗ
អមនុស្សា អតិពលា ហន្តារំ ជនយន្តិហា
អយោមយេហិ ជាលេហិ បីឡយន្តិ បុនប្បុនំ
តំ បស្សំ សកា គត្តា រុធិរំ អត្តសម្ភវំ
តម្ពលោហវិលីនំវ តត្តំ បាយេន្តិ មត្តិយំ ៗ
ជិគុច្ឆំ កុណបំ បូតិទុគ្គន្ធំ គូថកទ្ទមំ

បុព្វលោហិតសង្កាសំ វហោទោគយ្ហ តិដ្ឋតិ
តមេនំ កិមិយោ តត្ថ អតិកាយោ អយោមុខា
ឆវិំ ភេត្វាន ខាទន្តិ បគិទ្ធា មំសលោហិតេ ។
សោ ច តំ និរយំ បត្តោ និមុគ្គោ សតបោរិសំ
បូតិកំ កុណបំ វាតិ សមន្តា សតយោជនំ ។
ចក្ខុមាបិ ហិ ចក្ខូហិ តេន គន្ធេន ជីរតិ
ឯតាទិសំ ព្រហ្មទត្ត មាតុឃាតី លភតេ ទុក្ខំ ។

## ពាក្យប្រែ

បុត្រដែលសម្លាប់មាតាគ្រាទៅចាកលោកនេះហើយ រមែងធ្លាក់នរក បានទទួលផលកម្មរបស់ខ្លួនសោយទុក្ខដ៏ខ្លាំងក្លា ៗ ពួកនាយនិរយបាល ដែលមានកំឡាំងខែងរែង រមែងទូន្មានសត្វនរកអ្នកសម្លាប់មាតាដោយ នង្គ័លដែករៀយ ៗ ខ្លះ ឲ្យផឹកស៊ីលោហិតរបស់ខ្លួនឯងខ្លះ ឲ្យស៊ីទឹក ទន់ដែងដ៏ក្តៅខ្លះ ៗ បន្ទាប់ឲ្យមុចចុះទៅក្នុងទឹក ដែលដូចគ្នានឹងទឹក ខ្ទុះទឹករលាម សឹងផាទឹត្បួរទ្រើមល្មើមដូចសាកសព ដូចយ៉ាងគូថខ្លះ ៗ ពួកដង្កូវមាត់ដែកខ្លួនធំ ដែលមាននៅក្នុងទឹកនោះ ចោះស៊ីសាច់នឹង

ឈាមរបស់សត្វនរកនោះខ្លះ ។ សត្វនរកនោះ រមែងមុជចុះទៅក្នុងទឹក គឺស្អុយដូចសពខ្មោច មានក្លិនអសោចផ្សាយទៅតាំងរយយោជន៍ ដ៏ជ្រៅចុះទៅតាំងរយព្យាមមនុស្សខ្លះ ។ មនុស្សដែលមានភ្នែកល្អ កាលឃើញនឹងខ្ទប់ភ្នែកព្រោះទឹកសំអុយ ដែលមានក្លិនដ៏ស្អុយមកនោះ ( អធិប្បាយ-ថា មនុស្សយើងរមែងមិនត្រូវការមើលរបស់ដែលមានក្លិនស្អុយ កាលឃើញហើយក៏ងាកមុខចេញខ្លះ បិទភ្នែកខ្លះក៏មាន ) អ្នកសម្លាប់មាតារមែងបានទទួលទុក្ខដូចនេះ ។

៦- ឱធារមន្ទកម្ម តិក្ខំ ទុរភិសម្ភវំ
បតន្តិ គព្ភបាតិនិយោ ទុគ្គំ វេតរណឹ នទឹ ។

## ពាក្យប្រែ

ពួកស្រីដែលធ្វើគភ៌ឲ្យធ្លាក់ រមែងធ្លាក់វេតរណីនទី ដែលមានបន្លាដែកដ៏ស្រួចមុត ដកចេញឬជៀសគេចបានដោយក្រ ។

៧- អយោមយា សិម្ពលិយោ សោឡសង្គុលិកណ្ណកា
ឧភតោ មលិលព្ភន្តិ ទុគ្គំ វេតរណឹ នទឹ ។
តេ អច្ចិមន្តោ តិដ្ឋន្តិ អគ្គិខន្ធាវ អារកា

អាទត្តា ជាតវេទេន ឧទ្ធំ យោជនមុគ្គតា
ឯតេ សជន្តិ និរយេ តត្តេ តិវិណកណ្ឋកេ
នារិយោ ច អតិចារិនិយោ នរាច បរទារគូ ។
តេ បតន្តិ អធោក្ខន្ធា វិត្តា វិហតា បុថុ
សយន្តិ វិនិវិទ្ធង្គា ទីឃំ ជគ្គន្តិ សំវរី ។
តតោ រត្យា វិវសនេ មហតី បព្វតូបមំ
លោហកុម្ភី បវជ្ជន្តិ តត្តំ អគ្គិសមុទកំ ។
ឯវំ ទិវា ច រត្តោ ច ទុស្សីលា មោហបារុតា
អនុភោន្តិ សកំ កម្មំ បុព្វេ ទុក្កតមត្តនោ ។

## ពាក្យប្រែ

មានដើមរកាដែកបន្លាប្រវែង ១៦ អង្គុលីមានរមែកទោចុះ ហ៊ុំដំ
វេតរណីនទីនរកទាំងពីរ ផ្លូវដែលជាស្ពានដែលទីឆ្លងបានដោយក្រ ។
សត្វនរកទាំងនោះ សឹងតែមានខ្លួនកំពស់មួយយោជន៍ ខ្លួននេះ
ជាភ្លើងដូចគំនរភ្លើងធំ ដែលត្រូវភ្លើងនេះ ។
ស្រីដែលប្រព្រឹត្តក្រៅចិត្តស្វាមី និងប្រុសដែលខូចនឹងភរិយាអ្នក

ដាវែទ ត្រូវផ្ទាក់សិម្ពលីនរកដែលពេញទៅដោយដើមរកា មានបន្លាដ៏ស្រួច មុតដេះដោះណ្តាតភ្លើង សត្វនរកទាំងនោះរមែងត្រូវនាយនិរយបាលចាក់ ដោយអាវុធ ហើយយកក្លាវការទម្លាក់ចុះមកចាកដើមរកា ដេកនៅទីង ផែនដែកក្រហមអស់រាត្រីកាលដ៏យូរ ។

លុះព្រឹកឡើងក៏ត្រូវពួកនាយនិរយបាលចាប់បោះចុះទៅក្នុងខ្ទះទង់-ដែងធំប៉ុនភ្នំ ដែលពេញទៅដោយទឹកទង់ដែងដ៏ក្តៅពន្លឹក ។

ពួកសត្វនរកដែលជាអ្នកទ្រុស្តសីល លុះអំណាចនៃមោហៈទាំងនោះ សោយផលកម្មដែលខ្លួនធ្វើក្នុងកាលមុន ទាំងយប់ថ្ងៃដោយ អាការៈយ៉ាងនេះ ។

៨-យោ ច ភរិយា ធនក្កីតា សាមិកំ អតិញ្ញាតិ
សស្សុំ វា សស្សុរំ វា បិ ជេដ្ឋំ វាបិ ននន្ទនំ
តស្សា វង្កេន ជិវ្ហគ្គំ និព្វហន្តិ សពន្ធនំ ។
សព្យាមមត្តំ កិមិនំ ជិវ្ហំ បស្សតិ អត្តនោ
វិញ្ញាបេតុំ ន សក្កោតិ តាបនេ បេច្ច បច្ចតិ ។

ពាក្យប្រែ

ស្រីណាមើលងាយស្វាមី ឬមើលងាយឪពុកម្ដាយក្មេកបងប្អូនក្មួយរបស់ប្ដី ស្រីទាំងនោះរមែងត្រូវនាយនិរយបាលកៀបថ្គាមអណ្ដាតដោយសន្ទូចឲ្យលៀនចេញទៅ ។

ស្រីនោះឃើញអណ្ដាតរបស់ខ្លួនដែលលៀនចេញវែងមក ពេញទៅដោយពួកដង្កូវរមែងមិនអាចទ្រាំមើលបាន ក៏ស្លាប់ទៅកើតក្នុងតាបននរកទៀត ។

៩ – ឱរព្ភិកា សូករិកា មច្ឆិកា មិគពន្ធកា

ចោរា គោឃាតកា លុទ្ទា អវណ្ណេ វណ្ណការកា

សត្តីហិ លោហកូដេហិ នេត្តឹសេហិ ឧសូហិ ច

ហញ្ញមានា ខារនទឹ បបតន្តិ អវំសិរា

សាយំ បាតោ កូដការី អយោកូដេហិ ហញ្ញតិ

តតោ វន្តំ ទុរត្តានំ បរេសំ ភុញ្ជតេ សទា

ធង្កា ភេរណ្ឌកា គិជ្ឈា កាកោលា ច អយោមុខា

វិប្ផន្ទមានំ ខាទន្តិ នរំ កិព្ពិសការិនំ

យេ មិគេន មិគំ ហន្តិ បក្ខឹ វា បន បក្ខិនា

# អសន្តោ រជសា ឆន្នា គន្ត្វា តេ និរយស្សុទំ ។

## ពាក្យប្រែ

អ្នកសម្លាប់ពពែ សម្លាប់ជ្រូក សម្លាប់ត្រី ដក់ឡើ ធ្វើចោរកម្ម សម្លាប់គោ ជានាយព្រាន អ្នកសឹកសៀត ។

ពួកនេះ រមែងត្រូវនាយនិរយបាលចាក់ដោយលំពែង វាយដោយញញួរដែក សាប់ដោយដាវ បាញ់ដោយកូនសរ ហើយកាត់យកក្បាលបោះចុះទៅកាន់ឋានទីនរក ។

មនុស្សដែលធ្វើសេចក្ដីកោង ត្រូវពួកនាយនិរយបាលវាយសំពង ដោយញញួរដែកទាំងព្រឹកល្ងាច នឹងត្រូវបានស៊ីរបស់ដែលពួកសត្វនរកដទៃ ៗ ដែលមានរាងកាយទាល់ទុក្ខវេទនាសម្រក់ចេញមកគ្រប់កាល ។

ពួកក្អែក ក្ងែ ត្មាត មាត់ចំពុះជាដែកក៏កាត់ចឹកស៊ីសត្វនរក ដែលធ្លាប់ធ្វើអំពើអាក្រក់ទុកកាលមុន នឹងឆេះក្ដៅនៅក្នុងនរក មនុស្សពួកណាដែលជាអសប្បុរសដែលលុះអំណាចនៃកិលេសឲ្យសត្វម្រឹគបក្សី ដល់ចឹកប្រមាំ មនុស្សពួកនោះត្រូវទៅធ្លាក់ចុះក្នុងឧស្សុទនរក ។

(ចប់និរយកថាក្នុងសង្កិច្ចជាតក)